# នារទព្រហ្មជាតក



នេះកាលព្រះមហានារទព្រហ្មពោធិសត្វ ទូន្មានធម៌
ដល់ព្រះបាទអង្គតិរាជ និងបុត្រីព្រះនាមរុចា


ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ

**កុល ផេង**



**ព.ស. ២៥៦៣**

# មហានារទកស្សបជាតកពិស្តារ

## អធិបតីក្នុងការរៀបរៀង
## បណ្ឌិត កុល ផេង

*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## អ្នកបកប្រែពីអដ្ឋកថាភាសាបាលី

*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

## ក្រុមជំនុំពិនិត្យ

*បណ្ឌិត* **កុល ផេង** *ប្រធាន*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា**

*ព្រះញាណកោសល* **យ៉ន សេងយៀត**

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*បណ្ឌិត* **ប៉ក់ ថាវិន**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*លោក* **លឹម ឈឿម**

*លោក* **ដុង សុភឿន**

*លោក* **ទិព្វ សៅ**

*លោក* **សំណាង សំណាក់**

*លោក* **ស៊ន់ គីមឈន់**

*លោក* **ប៉ាល់ ចំរើន**

*លោក* **ហ៊ុន ពិសេស**

*លោក* **ហាន សុខេមន្ទ** *លេខាធិការ*

## ក្រុមបច្ចេកទេស និងរចនា

*លោក* **អ៊ិន ស៊ីយ៉ុន្ដា** *ប្រធាន*

*លោក* **ម៉ម ម៉ានិត** *អនុប្រធាន*

*លោក* **ឃុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

## រចនាសម្ព័ន្ធពុទ្ធិកបណ្ឌិតសភា<br>នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា<br>ក្រុមប្រឹក្សាភិបាល និងស្ថាបនិក

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះធម្មឃោសាចារ្យ* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សាមឿន** *សមាជិក*

*ព្រះមហា* **គួ សុភាព** *សមាជិក*

*បណ្ឌិត* **ជា សានចាន់ថន** *សមាជិក*

*បណ្ឌិត* **ប៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គីមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **រស់ សារេវន** *សមាជិក*

*សាស្ត្រាចារ្យ* **ជិត ជន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា គ្រិស្នា** *សមាជិក*

*សាស្ត្រាចារ្យ* **អ៊ុង សុវណ្ណា** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **ភុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធានគណៈកម្មការត្រួតពិនិត្យ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោក* **ហ៊ាត ណាហំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមន្ទ** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **ភុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះទេពសត្ថា* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *ប្រធាន*

*ព្រះមហា សក្យមុនីបុត្តោ* **ជា សុមាលា** *សមាជិក*

*លោក* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **ចាន់ ហួរ** *សមាជិក*

*លោក* **ហួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះញាណកោសល* **យ៉ន សេងយៀត** *ប្រធាន*

*ព្រះមហា* **គូ សុភាព** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ ភុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **លឹម លឿម** *សមាជិក*

*លោក* **សំណាង សំណាក់** *សមាជិក*

*លោក* **ដុង សុភឿន** *សមាជិក*

*លោក* **ហ៊ុន ពិសេស** *សមាជិក*

*លោក* **ស៊ន់ គឹមឈយន់** *សមាជិក*

# សូមថ្វាយព្រះរាជកុសល
# ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង
# ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## *បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "* **មហានារទកស្សបជាតកពិស្តារ** *" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *សូម* **ព្រះករុណាជាអម្ចាស់** *អនុមោទនានូវមហា*

កុសល ដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុងអនាគត និងដោយអំណាចគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលថែរក្សា **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូម **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,

ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨

**កុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមថ្វាយព្រះរាជកុសល
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

## *បពិត្រសម្តេចព្រះមហាក្សត្រីជាអម្ចាស់ជីវិតតម្កល់លើត្បូង*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយ ព្រះសព្ទសាធុការពរបវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ* "**មហានារទកស្សបជាតកពិស្តារ**" *តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនានូវមហាកុសលដោយព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះ បារមីនៃព្រះ*

*សម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់កន្លងមកក្នុង ហើយនឹងត្រាស់ដឹងក្នុងអនាគត និងដោយអំណាចគុណបុណ្យ ព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមី នៃអតីតៈព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលថែរក្សា* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់មានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **សម្តេចព្រះមហាក្សត្រី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,*
*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**កុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមគោរពជូនមហាកុសល
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## *សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់*

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាខ្ញុំបាទ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តីជយមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ* **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូនមហាកុសល ដែលខ្ញុំបាទបានដឹកនាំការរៀបរៀងចងក្រងនូវសៀវភៅ* "**មហានារទកស្សបជាតកពិស្តារ**" *តម្កល់ទុកក្នុងព្រះពុទ្ធសាសនានេះ ។ សូម* **សម្តេច** *និង* **លោកជំទាវ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ។ ដោយតេជះគុណានុភាពនៃព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុសក្តិសិទ្ធិ ក្នុងលោក សូមជួយបីបាច់ថែរក្សានិងប្រសិទ្ធិពរជ័យជូន* **សម្តេច** *និង* **លោកជំទាវ** *ព្រមទាំង* **បុត្រាបុត្រី** *និង* **ចៅ** *ៗ ជាទីស្រឡាញ់របស់*

**សម្តេច** *សូមមានសុខភាព ល្អបរិបូណ៌ ជន្មាយុយឺនយូរ បញ្ញាញាណ វាងវៃ ដើម្បីដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកត្រើយសុខសន្តិភាព និងការអភិវឌ្ឍឲ្យសម្បូរសប្បាយ រុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។*

*ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្តនូវវីរិយភាពដ៏អង់អាចរបស់* **សម្តេច** *ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែងរកសេចក្តីសុខជូនចំពោះប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុងព្រះរាជាណាចក្រកម្ពុជាយើង នាំមកនូវភាពចម្រើនរុងរឿង នាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគតកាល ។*

*សូម* **សម្តេចអគ្គមហាសេនាបតីតេជោ** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** *ប្រកបដោយសិរីមង្គល វិបុលសុខមហាប្រសើរ ព្រមទាំងទទួលបាននូវធម៌ដ៏ប្រសើរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។*

*រាជធានីភ្នំពេញ,*
*ថ្ងៃ ៩ កើត ខែ អស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**ភុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# បុព្វកថា

*រឿងមហានារទកស្សបៈនេះ គឺជាជាតកមួយក្នុងមហាទសជាតក៍ ដែលមានប្រភពដើមជាភាសាបាលីនៃគម្ពីរអដ្ឋកថា ។ យើងដឹងហើយថា នៅប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ មានអ្នកចេះភាសាបាលីជាស្ថានសម្រាប់ចូលទៅស្វែងយល់នូវពុទ្ធវាទជាភាសាបាលីនេះ មានចំនួនតិចតួច ។ បើទុករឿងក្នុងជាតកទាំងអស់ឲ្យនៅជាភាសាបាលីដូច្នេះ ជាឧបសគ្គដ៏ធំសម្រាប់អ្នកសិក្សាភាគច្រើន រួមទាំងសិស្ស និស្សិត និងបញ្ញវន្តទាំងអស់ដែលមិនបានសិក្សាភាសាបាលី ។ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាយើង ក៏ធ្លាប់មានសៀវភៅសង្ខេបទសជាតក ដែលប្រែនិងរៀបរៀងដោយលោក* ***ឈឹម ស៊ុម*** *កាលពីឆ្នាំ ១៩៥៩ មួយក្បាលគ្រប់ទាំង ១០ រឿងរួចមកហើយ ឃើញថា មានសេចក្ដីសមល្មមគ្រប់គ្រាន់សម្រាប់ពុទ្ធសាសនិកជនសម័យនោះសិក្សារៀនសូត្រ តែមកដល់សម័យបច្ចុប្បន្ននេះ រឿងសង្ខេបទសជាតកនោះ មិនទាន់ជួនល្មមដល់តម្រូវការនៃការស្រាវជ្រាវរបស់សិស្ស និស្សិត បញ្ញវន្ត និងពុទ្ធសាសនិកនៅឡើយ ។*

*សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា មើលឃើញពីតម្រូវការនេះ ថាជាការចាំបាច់បំផុតក្នុងការចូលរួមចំណែកជួយអប់រំសង្គម ទើបខ្ញុំខ្មែរ ចាត់ចែង រៀបចំបកប្រែនិងរៀបរៀងមហានារទកស្សបជាតក*

នេះ ម្តងទៀតឲ្យមានសេចក្តីពិស្តារ តាមច្បាប់ដើមក្នុងអដ្ឋកថា ជាភាសាបាលី ក្នុងគោលបំណងជួយបំពេញបន្ថែមដល់ការសិក្សាស្រាវជ្រាវរបស់ សិក្ខាកាមគ្រប់កម្រិតនិងដល់ពុទ្ធបរិស័ទគ្រប់រូប ។

ការរៀបរៀងសៀវភៅនេះ ដំបូងយើងប្រែពីភាសាបាលីមកជាភាសាខ្មែរ បន្ទាប់មក យើងចាប់ពិនិត្យកែសម្រួលអក្ខរាវិរុទ្ធ ដោយប្រើសំនួនវោហារតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួន-ណាត ជោតញ្ញាណោ ជាគោល ។ ខ្លឹមសារសេចក្តី យើងប្រើពាក្យពាយសាមញ្ញ ងាយអាន ងាយស្តាប់ ងាយយល់ ដល់អ្នកសិក្សាគ្រប់កម្រិត ។ ម្យ៉ាងទៀត ពាក្យពិបាកខ្លះដែលជាប់ដោយភាសាបាលី ដែលខ្មែរយកមកប្រើជាពាជសព្ទ និងសង្ឃសព្ទ យើងមិនអាចចៀសវាងបាន ក៏ត្រូវរក្សាទុក ដោយដាក់លេខយោងពន្យល់នៅផ្នែកខាងក្រោមនៃទំព័រ ។

ពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លា ល្បះ និងខ្លឹមសារសេចក្តីក្នុងសៀវ-ភៅនេះ ទោះបីយើងខំប្រឹងប្រែងពិនិត្យកែជាច្រើនលើកច្រើនសា ដោយផ្ចិតផ្ចង់ក៏ដោយ ក៏គង់មានចំណុចខ្វះចន្លោះផ្នែកអក្ខរាវិរុទ្ធ និងសេចក្តីនៅមានផ្តាំផ្តងខ្វះ ៗ មិនខាន ។ សូមអស់លោកអ្នកអានឃើញខុសត្រង់ណា មេត្តាជួយកែតម្រូវក្នុងលក្ខណៈស្ថាបនាឲ្យបានរីកចម្រើន ដើម្បីបានជាក្បួនខ្នាតទុកសម្រាប់កុលបុត្រសិក្សាតទៅអនាគត ។

សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមចែករំលែកនូវកងការមហាកុសលដែលកើតឡើងពីការបកប្រែរៀបរៀងសៀវភៅមហានារទ

*កុសលប្រជាតកពិស្តារនេះ ថ្វាយ ប្រគេន ជូនដល់អស់លោកអ្នកដែលបានកាន់សៀវភៅនេះអាន និងដល់បុព្វការីជន ញាតិមិត្រ សាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ដ សូមឲ្យលោកអ្នកមានគុណទាំងនោះបានសម្រេចនូវសម្បត្តិ ៣ គឺសម្បត្តិមនុស្ស សម្បត្តិទេព្តា និងសម្បត្តិព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។*

*សូមសត្វលោកទាំងពួងបានប្រកបដោយសេចក្ដីសុខជានិរន្តរ៍តទៅ ។*

*រាជធានីភ្នំពេញ,*

*ថ្ងៃ ៩ កើត ខែអស្សុជ ឆ្នាំ មមី ឆស័ក ព.ស. ២៥៥៨*

**គុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# មាតិកា

## ជំពូកទី ១

*ស្ដេចអង្គតិក្នុងក្រុងមិថិលាដែនវិទេហៈ*


*ខាងដើមនិទាន...............................................................១*

*ជដិល ៣ នាក់បងប្អូន......................................................១*

*សំណួរស្ដេចអង្គតិចំពោះពួកមន្ត្រី.......................................៨*

*យោបល់មន្ត្រី ៣ នាក់.......................................................៩*

*ស្ដេចអង្គតិចូលទៅរកអចេលក៍...........................................១១*

*សេចក្ដីសន្ទនារវាងស្ដេចអង្គតិនិងអចេលក៍..........................១៥*

*យោបល់អលាតសេនាបតី..................................................២១*

*យោបល់ទាសៈឈ្មោះជីវកៈ...............................................២២*


## ជំពូកទី ២

*ស្ដេចអង្គតិប្រកាន់ទស្សនៈខុស*

ព្រះបាទវិទេហៈលះបង់រាជកិច្ច........................................២៨

ព្រះរាជធីតារុចាចូលគាល់ព្រះបិតា....................................៣០

ព្រះរាជធីតាបន្ទោសការសេពគប់បុគ្គលពាល......................៣៥

ព្រះរាជធីតាបង្ហាញពីអតីតជាតិ........................................២៣

## ជំពូកទី ៣

### ស្តេចអង្គតិរកផ្លូវសេចក្តីបរិសុទ្ធិឃើញ

រាជធីតារុចាតាំងសច្ចាធិដ្ឋាន..............................................៥២

មហាព្រហ្មនារទៈ..............................................................៥៦

សំណួរចម្លើយនៃនារទៈនិងព្រះរាជា..................................៥៩

នារទៈថ្លែងនិរយកថា........................................................៦៥

នារទៈសម្តែងផ្លូវនៃសេចក្តីបរិសុទ្ធិ.......................................៧១

ព្រះសាស្តាប្រជុំជាតក.........................................................៨១

# ជំពូកទី ១

## ស្តេចអង្គតិក្នុងក្រុងមិថិលាដែនវិទេហៈ

### ខាងដើមនិទាន

*កាលព្រះសាស្តាគង់នៅក្នុងឧទ្យានលដ្ឋិវ័ន ទ្រង់ប្រារព្ធនូវការទូន្មានឧរុវេលកស្សប ហើយសម្តែងនូវធម្មទេសនានេះ មានពាក្យថា "អហុ រាជា វិទេហានំ" ដូច្នេះជាដើម ។*

*មានសេចក្តីពិស្តារថា ក្រោយពេលព្រះសាស្តាញ៉ាំងធម្មចក្រដ៏បវរឲ្យប្រព្រឹត្តទៅ ព្រះអង្គបានទូន្មានជដិល ៣ នាក់ មានជដិលឈ្មោះឧរុវេលកស្សបជាដើម ហើយព្រះអង្គមានបុរាណជដិល ១.០០០ នាក់ជាបរិវារ ។ ស្តេចយាងទៅកាន់ឧទ្យានលដ្ឋិវ័នដើម្បីដោះពាក្យប្តេជ្ញាដែលព្រះអង្គបានសន្យាជាមួយនឹងព្រះបាទពិម្ពិសារ ស្តេចនៃដែនមគធៈ ។ គ្រានោះ ព្រះបាទពិម្ពិសារព្រមទាំងបរិពារ ១២ នហុត[១] យាងមកថ្វាយបង្គំព្រះទសពល រួចប្រថាប់គង់ ។ ព្រាហ្មណ៍និងគហបតីទាំងឡាយ ក្នុងចន្លោះបរិស័ទនោះមានសេចក្តីត្រិះរិះកើតឡើងថា ៖*

---

*[១] (ប. សំ.) (បា.) (ន.) ម៉ឺន (១០.០០០) ។ ចំនួនមួយរយសែនកោដិបកោដិ ក៏ហៅនហុតដែរ ។*

"ឱរុវេលកស្សប ប្រព្រឹត្តព្រហ្មចរិយៈ[២]ក្នុងសម្នាក់មហាសមណៈ
ទេដឹង ឬថាមហាសមណៈប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់
ឱរុវេលកស្សបវិញ" ។

លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់បរិស័ទទាំងនោះដោយចិត្តរបស់ព្រះអង្គ ទើបទ្រង់មានព្រះតម្រិះថា ៖

"អញតថាគតនឹងធ្វើឲ្យបរិស័ទទាំងនេះដឹងថា កស្សបបួសក្នុង
សម្នាក់របស់អញតថាគត" ។

លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ទ្រង់ត្រាស់ថា ៖

"កិមេវ ទិស្វា ឩរុវេលវាសិ បហាសិ អគ្គឹ
កិសកោវទានោ;

---

[២] ព្រហ្មចរិយ ឬ ព្រហ្មចារ្យ ន. (បា. ព្រហ្មចរិយ សំ. ព្រហ្មចយ៌) បែបបទ ឬសណ្តាប់ធ្នាប់របស់ព្រហ្មចារី ឬព្រហ្មចារិនី; ការប្រព្រឹត្តធម៌ដ៏ប្រសើរ ។ តាមន័យខាងពុទ្ធសាសនាថា ការឲ្យទាន ការខ្វល់ខ្វាយ ឬខ្នះខ្នែងចំពោះអំពើជាកុសល ការរក្សាសីល ៥ ការចម្រើនព្រហ្មវិហារ ៤ ការសម្តែងធម៌ ឬណែនាំពន្យល់ឲ្យអ្នកដទៃកាន់អំពើសុចរិត ការវៀរចាកមេថុនធម្ម សេចក្តីសន្តោសចំពោះភរិយារបស់ខ្លួន សេចក្តីព្យាយាមដ៏ខ្ជាប់ខ្ជួនក្នុងការកុសល ការរក្សាឧបោសថសីលតាមកាលកំណត់ អរិយមគ្គ ព្រះពុទ្ធសាសនាទាំងមូល អធ្យាស្រ័យ (ទាំង ១២ យ៉ាងនេះ) ហៅថា ព្រហ្មចរិយ ឬ ព្រហ្មចារ្យ

បុច្ឆាមិ តំ កស្សប ឯតមត្ថំ  កថំ បហីនំ តវ អគ្គិហុត្តំ ។

"អ្នកឯងនៅក្នុងឧរុវេលប្រទេស ជាអ្នកប្រដៅពួកតាបស តើអ្នកឃើញអ្វី បានជាលះបង់ការបូជាភ្លើងចោល ។ ម្នាលកស្សប តថាគតសួរសេចក្តីនេះនឹងអ្នក ការបូជាភ្លើងដែលអ្នកលះបង់ហើយ តើព្រោះហេតុអ្វី ?"

ចំណែកព្រះថេរៈឧរុវេលកស្សប ដឹងនូវបំណងរបស់ព្រះមានព្រះភាគ បានក្រាបបង្គំទូលថា ៖

"រូបេ ច សទ្ទេ ច អថោ រសេ ច, កាមិត្ថិយោ ចាភិវទន្តិ យញ្ញា;
ឯតំ មលន្តិ ឧបធីសុ ញត្វា, តស្មា ន យិដ្ឋេ ន ហុតេ អរញ្ជឹ" ។

"ជនទាំងឡាយតែងពោលសរសើរនូវកាមទាំងឡាយ គឺ រូប សំឡេង ព្រមទាំងរសផង នូវស្រីទាំងឡាយផង ព្រោះការបូជា ខ្ញុំព្រះអង្គដឹងថា កាមគុណមានរូបជាដើមនេះ ជាគ្រឿងសៅហ្មង ក្នុងឧបធិ[៣] ទាំងឡាយ ព្រោះហេតុដូច្នោះ ខ្ញុំព្រះអង្គមិនត្រេកអរ ក្នុងការបូជាធំនិងការបូជាតូច គឺការគោរពភ្លើងរាល់ថ្ងៃទេ" ។

---

[៣] (ន.) (សំ.),(បា.) (អ៊ុប៉ៈធិ) កិលេស, កិលេសជាគ្រឿងទាក់ទិន; ដំណើរធបោក, ប្រវ័ញ្ចន៍, ការបញ្ឆោត; កិរិយាកោងកាច ។

ដើម្បីប្រកាសខ្លួនជាសាវ័ក ឱរុវេលកស្សបដាក់សីសៈលើខ្នងព្រះបាទា របស់ព្រះតថាគត រួចពោលថា ៖

"បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាបរមគ្រូនៃខ្ញុំព្រះករុណា ខ្ញុំព្រះករុណាជាសាវ័ករបស់ព្រះអង្គ" ។

រួចហោះទៅឰដ៏អាកាសវេហាស៍ បានកម្ពស់ប្រវែងមួយដើមត្នោត ហើយចុះមកវិញ រួចហោះទៅម្តងទៀត បានកម្ពស់ប្រវែងពីរដើមត្នោត ហើយចុះមកវិញ ហោះបែបនេះ ៧ ដង រហូតបានកម្ពស់ប្រវែង ៧ ដើមត្នោត ចុះមកវិញហើយថ្វាយបង្គំព្រះមានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះបានឃើញនូវបាដិហារ្យដូច្នោះ មហាជនស្ងើចសរសើរដល់គុណព្រះសាស្តាថា ៖

"អហោ មហានុភាវោ ពុទ្ធោ ឯវំ ថាមគតមិច្ឆិកោ នាម អត្តានំ 'អរហា'តិ មញ្ញមានោ ឧរុវេលកស្សបោបិ ទិដ្ឋិជាលំ ភិន្ទិត្វា តថាគតេន ទមិតោ" ។

"ឱ អានុភាពព្រះពុទ្ធជាម្ចាស់ខ្លាំងអ្វីម៉្លេះហ្ន៎ ! អម្បាលគ្រូដ៏ល្បីឱរុវេលកស្សប មានទិដ្ឋិរឹងត្អឹង[៤] សម្គាល់ខ្លួនថាព្រះអរហន្តម៉្លឹងហើយ គង់ត្រូវព្រះសាស្តាបំបែកបណ្តាញទិដ្ឋិ[៥]ចេញ ហើយទូន្មានបាន" ។

ទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះសាស្តាត្រាស់ថា ៖

"កិច្ចការដែលតថាគតទូន្មានឱរុវេលកស្សបក្នុងពេលសម្រេចសព្វញ្ញុតញ្ញាណ[៦] ក្នុងកាលឥឡូវនេះ មិនមែនអស្ចារ្យទេ, កាលពីអតីត ដែលកំពុងមានរាគៈនៅឡើយ តថាគតនោះកើតជាព្រហ្មឈ្មោះនារទៈ ក៏ធ្លាប់បានបំបែកបណ្តាញទិដ្ឋិរបស់ឱរុវេលកស្សបនេះ ហើយធ្វើឲ្យលែងមានសេចក្តីរឹងត្អឹងអ៊ីចឹងដែរ ក្នុងកាលនោះ ទើបអស្ចារ្យ" ។

---

[៤] មានទិដ្ឋិយល់ខុសហើយចចេសរបឹងរឹងរូសមិនងាយនរណាកែប្រែបាន ។

[៥] ទិដ្ឋិរបរឹតចាក់ស្រេះចាក់កណ្តាញ់ស្មុគស្មាញខ្លាំង ដោះមិនចេញស្រាយមិនរួច ។

[៦] ញាណឬប្រាជ្ញាដែលដឹងសព្វគ្រប់ ញាណនេះមានសម្រាប់តែព្រះពុទ្ធអង្គប៉ុណ្ណោះ ព្រះបច្ចេកពុទ្ធ ឬ សាវ័កពុទ្ធ មិនអាចមានញាណនេះទេ។

ពួកបរិស័ទអារាធនាព្រះបរមគ្រូឲ្យទ្រង់សម្ដែងរឿងនេះឲ្យបានជាក់ច្បាស់ ទើបព្រះអង្គទ្រង់នាំអតីតនិទានមកតំណាលដូចតទៅ ៖

ក្នុងអតីតកាល មានព្រះរាជាមួយអង្គ ព្រះនាមថា **អង្គតិ** សោយរាជសម្បត្តិក្នុងក្រុងមិថិលា ដែនវិទេហៈ ទ្រង់ប្រកបដោយធម៌ ជាធម្មរាជា[៧] មានយានច្រើន មានទ្រព្យច្រើន មានពលច្រើនឥតគណនា ។ មានព្រះរាជធីតាមួយព្រះអង្គព្រះនាមថា **រុចា** ព្រះនាងមានរូបស្អាតគួរឲ្យគយគន់ ជាទីជ្រះថ្លា ព្រះនាងមានសេចក្ដីប្រាថ្នាតាំងទុកមកអស់ ១០០.០០០ កប្បមកហើយ ព្រះនាងជាអ្នកមានបុណ្យច្រើន ទើបបានមកកើតក្នុងផ្ទៃនៃអគ្គមហេសី ។ ចំណែកឯស្រីស្នំផ្សេង ៗ របស់ស្ដេចអង្គនោះ មានចំនួន ១៦.០០០ ។ រាជធីតានោះបានជាទីស្រឡាញ់ ជាទីសព្វព្រះទ័យរបស់ព្រះរាជាអង្គនោះ ។ ព្រះបិតាតែងបញ្ជូននូវផ្កានានាចំនួន ២៥ កញ្ច្រែងនិងសំពត់ទាំងឡាយដែលមានសាច់ល្អិតសុខុមកាត់ថ្លៃមិនបាន ដល់ព្រះរាជធីតាជារៀងរាល់ថ្ងៃ ថែមទាំងមានព្រះបន្ទូលផ្ដាំថា "ចូរបុត្រីយករបស់ទាំងនេះទៅប្រដាប់ព្រះកាយចុះ" ។

[៧] ព្រះរាជាដែលគ្រប់គ្រងរាស្ត្រប្រកបដោយធម៌ ហៅថា ធម្មរាជ។

និយាយពីខាទនីយៈ[៨]និងភោជនីយៈ[៩]វិញ ច្រើនលើសលុប ឥត ប្រមាណបាន ។ ជារៀងរាល់កន្លះខែ ព្រះមហាក្សត្រិយ៍តែងបញ្ជូន ប្រាក់ទៅ ១.០០០ កហាបណៈ ដើម្បីព្រះនាងបរិច្ចាគទានដោយព្រះ តម្រាស់ថា "ចូរព្រះនាងយកទ្រព្យនេះឲ្យទានចុះ" ។ ព្រះអង្គមាន អាមាត្យ ៣ នាក់ គឺវិជយៈអាមាត្យ ១ សុនាមៈអាមាត្យ ១ អលាតៈ អាមាត្យ ១ ។ ក្នុងព្រះនគរទាំងមូលទាំងក្នុងទីក្រុង ទាំងក្នុងព្រះរាជវាំង មានការរៀបចំតុបតែងលម្អយ៉ាងស្រស់ត្រកាល ដូចជាទេវនគរ ព្រោះ មានរៀបចំពិធីលេងមហោស្រពប្រព្រឹត្តទៅ ៤ ខែ ។ ស្តេចអង្គនោះ ស្រង់សុគន្ធវារី[១០]លាបលន[១១] ព្រះវរកាយ ប្រដាប់ដោយអលង្ការទាំង ពួង សោយក្រយាស្ងោយពេលល្ងាច ហើយទ្រង់មានគណៈរដ្ឋមន្ត្រី

---

[៨] អាហារសម្រាប់ទំពា (ពួកបង្អែម ឬ ចំណី) : ផ្លែឈើមានផ្លែស្វាយជាដើម ជា ខាទនីយ ។

[៩] ដែលគួរបរិភោគ, សម្រាប់បរិភោគ ។ ន. អាហារដែលគួរបរិភោគ ។

[១០] ទឹកក្រអូប ទឹកដែលមានលាយគ្រឿងក្រអូប ។

[១១] ធ្វើវត្ថុខាប់រាវឬផង់ ឲ្យជិតជាប់, ឲ្យជោក, ឲ្យប្រឡាក់; ផាត់ ហើយលនបន្ថែម ពណ៌ឲ្យរឹតតែមានសោភណថែមទៀតៈ លាបម្រ័ក្សហើយលនជាតិហិង្គុលពីលើ បន្ថែមទៀត ។

ចោមរោមក្នុងព្រះរាជមន្ទីរ[១២]ដែលមានសីហបញ្ជរ[១៣]បើក ហើយព្រះអង្គទ្រង់ទតឃើញនូវព្រះចន្ទពេញវង់មូលក្រឡង់រះត្រដែតឡើងនៅឯផ្ទៃនភាល័យ នៅពេលបឋមយាម ដែលមិនទាន់កន្លងនៃរាត្រីជាគម្រប់ ១៥ ជាទីបំផុតនៃខែភ្លៀង ៤ ខែ ជាទីរីកនៃផ្កាកុមុទ ព្រះអង្គទ្រង់ប្រជុំអាមាត្យឈ្មោះវិជយៈ ១ ឈ្មោះសុនាមៈ ១ និងសេនាបតីឈ្មោះអលាតៈ ១ ដែលជាបណ្ឌិត បរិបូណ៌ដោយការស្តាប់ជាអ្នកញញឹមមុននិយាយ ជាអ្នកមានប្រាជ្ញា ទ្រង់សួរអាមាត្យទាំងនោះ តាមលំដាប់ថា ៖

> "គួរឲ្យរីករាយអ្វីម៉្លេះទេ អស់លោកអើយ រាត្រីខាងខ្នើតនេះ, អ្នកទាំងឡាយ ចូរពោលតាមសេចក្តីពេញចិត្តផ្សេង ៗ គ្នា ក្នុងរាត្រីយប់នេះ ជារាត្រីជាទីបំផុតនៃខែភ្លៀង ៤ ខែ ជាទីរីកនៃផ្កាកុមុទ មណ្ឌលព្រះចន្ទដ៏ស កម្ចាត់បង់ងងឹត តើយើងទាំងឡាយនឹងនៅដោយសេចក្តីត្រេកអរដូចម្តេច ក្នុងរាត្រីរដូវនេះ ?"

---

[១២] រាជមន្ទីរ ព្រះរាជដំណាក់; ក្រុមព្រះរាជមន្ទីរ ក្រុមឱកាសមន្ត្រីឬក្រុមរឿនហ្លួង ។

[១៣] បង្អួចរបស់លោកអ្នកមានអានុភាពដូចសីហៈ គឺបង្អួចដំណាក់ឬប្រាសាទរបស់ក្សត្រិយ៍ទ្រង់រាជ្យ : ព្រះរាជាទ្រង់ប្រថាប់ក្បែរសីហបញ្ជរ ។ ឬ បង្អួចមានរង្វង់ដូចជាទ្រង់ជំហរសីហៈ ។

## យោបល់មន្ត្រី ៣ នាក់

ព្រះរាជាទ្រង់សួរមន្ត្រីទាំងឡាយដូច្នេះ ។ ពួកគេកាលដែលត្រូវស្តេចសួរហើយ ក៏បានបញ្ចេញនូវយោបល់ សមគួរតាមអធ្យាស្រ័យរៀង ៗ ខ្លួន ។ ជាលំដាប់ដំបូង សេនាបតីរបស់ព្រះរាជា ឈ្មោះអលាត: បានក្រាបទូលដូច្នេះថា ៖

"ខ្ញុំព្រះអង្គនឹងចាត់ចែងយាន ពល និងសេនាទាំងអស់ ដែលមានចិត្តអង់អាចក្លាហាន ។ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំមានពួកពលមិនមានទីបំផុត នឹងចេញទៅដើម្បីច្បាំង ។ ពួកព្រះរាជាណាមិនទាន់មកចុះចូលក្នុងអំណាចរបស់ព្រះអង្គ ។ ទូលព្រះបង្គំនឹងនាំចូលមកចុះក្នុងអំណាចព្រះអង្គ ។ នេះជាសេចក្តីយល់ផ្ទាល់ខ្លួនរបស់ទូលព្រះបង្គំ ពួកទូលព្រះបង្គំនឹងផ្ចាញ់សត្រូវដែលមិនទាន់ផ្ចាញ់ ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរក្នុងចម្បាំង នេះជាសេចក្តីចូលចិត្តរបស់ទូលព្រះបង្គំ" ។

ចំណែកអាមាត្យសុនាមៈ បានស្តាប់ពាក្យរបស់អលាតសេនាបតីហើយ ក៏ក្រាបទូលព្រះរាជាដូច្នេះថា ៖

"បពិត្រមហារាជ ពួកសត្រូវទាំងអស់បានធ្លាក់នៅក្នុងអំណាចរបស់ព្រះអង្គស្រាប់ហើយតើ ។ ពួកសត្រូវមានគ្រឿងសស្ត្រា

ដាក់ចុះហើយ តែងបាក់បបខូបខាច តែងប្រព្រឹត្តបន្ទន់បន្ទាប ។ មហោស្រពដ៏ឧត្តមនឹងមានក្នុងថ្ងៃនេះ ការច្បាំង ទូលព្រះបង្គំមិនពេញចិត្តទេ ។ ជនទាំងឡាយចូរនាំយកបាយទឹក និងបង្អែមយ៉ាងឆាប់មកថ្វាយព្រះអង្គ ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គត្រេកអរក្នុងការរាំច្រៀង និងគ្រឿងប្រគំ ដោយកាមទាំងឡាយចុះ" ។

វិជយាមាត្យវិញ បានស្តាប់ពាក្យរបស់សុនាមអាមាត្យហើយ ក៏ក្រាបទូលព្រះរាជាដូច្នេះថា ៖

"បពិត្រមហារាជ កាមទាំងអស់ប្រាកដដល់ព្រះអង្គជានិច្ចហើយតើ ។ បពិត្រព្រះសម្មតិទេព កាមទាំងនេះ ព្រះអង្គមិនមែនបានដោយក្រទេ កាលបើព្រះអង្គប្រាថ្នារីករាយដោយកាមទាំងឡាយ កាមទាំងឡាយ ព្រះអង្គបានសព្វ ៗ កាល នេះមិនមែនជាសេចក្តីពេញចិត្តរបស់ទូលព្រះបង្គំទេ ។ សមណព្រាហ្មណ៍ណា អ្នកដឹងអត្ថនិងធម៌[១៤] ជាអ្នកស្វែងរកគុណ អាចបន្ទោបង់នូវសេចក្តី

---

[១៤] ចេះបកស្រាយអធិប្បាយសេចក្តីនៃធម៌ ចេះដោះស្រាយបញ្ហាច្បាប់ឬប្រពៃណីទំនៀមទម្លាប់ ហៅថាដឹងអត្ថនិងធម៌។

សង្ស័យនៃយើងទាំងឡាយក្នុងថ្ងៃនេះបាន យើងទាំងឡាយនឹង ចូលទៅរកសមណព្រាហ្មណ៍ ជាពហុស្សូត[១៩]នោះ" ។

## ស្តេចអង្គតិចូលទៅរកអចេលក៍

ព្រះរាជាអង្គតិ ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់វិជយាមាត្យហើយ ទ្រង់ត្រាស់ថា ៖

"ការណ៍ដែលវិជយាមាត្យពោលនេះយើងសព្វរាជហឫទ័យណាស់ ។ សមណព្រាហ្មណ៍ដែលជាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណដែលអាចបន្ទោបង់សេចក្តីសង្ស័យរបស់យើងទាំងឡាយបាន ។ ក្នុងថ្ងៃនេះ យើងនឹងចូលទៅរកសមណ-ព្រាហ្មណ៍ជាពហុស្សូតនោះ ។ អ្នកទាំងអស់គ្នា ចូរធ្វើសេចក្តីយល់ថាតើយើងគួរចូលទៅរកបណ្ឌិតណា ដែលជាអ្នកដឹងអត្ថនិងធម៌ ជាអ្នកស្វែងរកគុណដ៏ធំ អាចកម្ចាត់បង់សេចក្តីសង្ស័យរបស់ពួកយើងបានក្នុងថ្ងៃនេះ" ។

---

[១៩] (ពហុគ្រុត; ពហុស្សុត) អ្នកដែលបានស្តាប់ច្រើន គឺអ្នកដែលរៀនបានច្រើន, ដែលមានចំណេះច្រើន : អ្នកពហុស្សូត; មនុស្សពហូសូត ។ ពហូសូត (ព:ហ៊ូ--)

អលាតសេនាបតី បានស្តាប់ព្រះបន្ទូលនៃព្រះបាទវិទេហៈហើយ ក៏ក្រាបទូលដូច្នេះថា ៖

"មានអចេលក៍[១៦] ១ អង្គ ដែលគេសន្មតថាជាអ្នកប្រាជ្ញ គង់ក្នុងមិគទាយវ័ន ។ អចេលក៍នេះ ឈ្មោះគុណៈ ជាកស្សបគោត្រ ជាអ្នកចេះដឹង ជាអ្នកពូកែខាងនិយាយថ្លៃងសេចក្តីយ៉ាងពីរោះក្បោះក្បាយ ជាគណាចារ្យ បពិត្រព្រះសម្មតិទេព យើងគួរចូលទៅរកអចេលក៍នោះ លោកនឹងអាចជួយផ្តល់មធ្យោបាយដើម្បីបន្ទោបង់សេចក្តីសង្ស័យនៃពួកយើងបាន" ក្រាបទូល ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនៃអលាតសេនាបតីហើយ ទ្រង់បង្គាប់នាយសារថីថា ៖

"យើងនឹងទៅកាន់មិគទាយវ័ន ដើម្បីជួបអចេលក៍អង្គនោះអ្នកចូរទៅយកយានដែលទឹមស្រេច មកទីនេះ" ។

---

[១៦] អ្នកមិនស្លៀកសំពត់ គឺអ្នកបួសពួកតិរ្ថិយដែលតមមិនស្លៀកសំពត់ ដោយប្រកាន់តាមលទ្ធិថាការប្រព្រឹត្តដូច្នេះ ជាគ្រឿងកម្ចាត់សេចក្តីលោកជាដើម (អ្នកបួសអាក្រាត) : ពួកអចេលក៍មានតែក្នុងប្រទេសឥណ្ឌា ។

*សារថីទាំងឡាយ ឮព្រះបន្ទូលរបស់ស្តេចអង្គនោះហើយ បាននាំគ្នាធ្វើតាមយ៉ាងនោះ ។*

តមត្ថំ បកាសេន្តោ សត្ថា អាហ *កាលនឹងប្រកាសសេចក្តីនោះឲ្យបានជាក់ច្បាស់ព្រះសាស្តាត្រាស់ថា ៖*

"តស្ស យានំ អយោជេសុំ ទន្តំ រូបិយបក្ខរំ;
សុក្កមដ្ឋបរិវារំ បណ្ឌរំ ទោសិនា មុខំ ។
តត្រាសុំ កុមុទាយុត្តា ចត្តារោ សិន្ធវា ហយា; អនិលូបម
សមុប្បាតា សុទន្តា សោណ្ណមាលិនោ ។
សេតច្ឆត្តំ សេតរថោ សេតស្សា សេតពីជនី;
វេទេហោ សហាមច្ចេហិ និយ្យំ ចន្ទោវ សោភតិ ។

*"ពួកនាយសារថី[១៧] បានទឹមយានជាវិការៈភ្លុក[១៨] មានទ្រូងជាវិការៈប្រាក់[១៩] ពណ៌សរលោងជាគ្រឿងលម្អបន្ថែម ប្រៀបដូចជាព្រះចន្ទពេញវង់ដែលគ្មានពពកបាំង ក្នុងពេលរាត្រី ។ រថនោះនាយ*

---

[១៧] *អ្នកបររថ; អ្នកបររទេះ; អ្នកបង្ហាត់សេះ ។*

[១៨] *យានធ្វើអំពីភ្លុក; យានភ្លុក ។*

[១៩] *យានធ្វើអំពីប្រាក់ យានប្រាក់ ។*

> សារថីទឹមសេះសិន្ធព[២០] ៤ មានសម្បុរដូចផ្កាកុមុទប្រដាប់គុបតែង ដោយកម្រងផ្កាជាវិការៈមាស សេះទាំងអស់នោះសុទ្ធតែជាសត្វ បានបង្ហាត់បង្ហឹករាបល្អហើយ ជាសត្វមានសន្ទុះលឿនដូចខ្យល់"។ ព្រះបាទវិទេហៈមានពួកអាមាត្យហែហមចោមរោម ល្អដូចជាព្រះចន្ទ្រ ទ្រង់យាងទៅដោយរថដែលប្រើវត្ថុពណ៌សទាំងអស់ គឺមានក្លស់ពណ៌ស រថពណ៌ស សេះស ស៊ែពណ៌ស" ។

ពួកពលដ៏អង់អាចក្លាហានជាច្រើននាក់ សុទ្ធតែជាអ្នកស្ទាត់ជំនាញក្នុងការប្រើលំពែងនិងដាវ បានជិះសេះតាមហែព្រះរាជាអង្គនោះ ដែលជាធំដ៏ប្រសើរជាងពួកជន ។ ព្រះបាទវិទេហៈអង្គនោះ ក៏យាងទៅកាន់ឧទ្យានដោយទ្រង់ជិះយានបានតែបន្តិច ទ្រង់ក៏ចុះចាកយាន ទ្រង់យាងផ្ទាល់ព្រះបាទ ជាមួយនឹងពួកអាមាត្យសំដៅទៅរកអចេលក៏ឈ្មោះគុណៈ ។ គ្រានោះ មានក្រុមព្រាហ្មណ៍និងគហបតីទាំងឡាយផ្សេងទៀតមកប្រជុំគ្នាមុនក្នុងឧទ្យាននោះដែរ បានឱកាសអង្គុយកៀកកិតជិតនឹងអចេលក៏ជាងព្រះរាជានិងបរិវាររបស់ព្រះអង្គ ជាហេតុធ្វើឲ្យព្រះរាជាមិនមានឱកាសទីកន្លែងសម្រាប់ទ្រង់ចូលទៅប្រថាប់គង់

[២០] ដែលជាប់ទាក់ទងដោយទន្លេសិន្ធុ សេះដែលកើតក្នុងដែនសិន្ធវៈ, សេះដែលមានពូជពីដែនសិន្ធវៈ (សេះទេស) : សេះសិន្ធព; ប្រើសំដៅសេចក្ដីត្រឹមតែ "សេះ" ក៏មាន ។

ជិតអចេលក៍សោះ ។ ព្រះរាជាក៏មិនបានទ្រង់ពិរោធក្រោធខឹង បណ្ដេញពួកព្រាហ្មណ៍និងគហបតីទាំងនោះទេ បែរជាទ្រង់ត្រាស់ថា ៖

> "អ្នកទាំងឡាយកុំព្រួយឡើយ ! ពួកយើងមកក្រោយអ្នកទាំងឡាយ វាជាកំហុសរបស់យើង" ។

**សេចក្ដីសន្ទនារវាងស្ដេចអង្គតិនិងអចេលក៍**

លំដាប់នោះ ព្រះរាជាត្រូវបរិស័ទជាច្រើនដែលនៅលាយឡំគ្នានោះចោមរោម យាងចូលទៅក្នុងទីសមគួរប្រថាប់លើពូកមានសម្ផស្សទន់[២១] លើកម្រាលដ៏វិចិត្រ មានសម្ផស្សទន់ លើទីដែលគេក្រាលដោយកម្រាលដ៏ទន់ ។ ព្រះរាជាលុះគង់ហើយ ធ្វើនូវបដិសណ្ឋារៈ[២២] ក៏បានចាប់ផ្ដើមសំណេះសំណាលរីករាយរាក់ទាក់ជាមួយនឹងអចេលក៍ ដោយទ្រង់ត្រាស់នូវពាក្យគួររលឹកថា ៖

---

[២១] ការប៉ះពាល់ត្រូវព្រមរាងកាយនឹងពូក ដោយសាច់ពូកហ្មត់ល្អ ការទទួលសម្ផស្សទន់ស្រួល គួរជាប់ជំពាក់ត្រេកត្រអាល ។

[២២] ការទទួលរាក់ទាក់ : ធ្វើបដិសណ្ឋារៈ, មានបដិសណ្ឋារៈ ។

"បពិត្រលោកដ៏ចម្រើន សរីរៈរបស់លោក អាចប្រព្រឹត្តទៅបានទេឬ? ធាតុខ្យល់មិនប្រព្រឹត្តទៅស្រួលក្នុងសរីរៈ[២៣]ទេឬ? ការស្វែងរកអាហារចិញ្ចឹមជីវិតរបស់លោក មិនលំបាកទេឬ? លោកបានដុំបាយខ្លះដែរឬ? លោកមិនមានអាពាធ[២៤]ទេឬ? ចក្ខុរបស់លោក មិនសាបសូន្យ ងងឹតស្រវាំងទេឬ?"

អចេលក៍ឈ្មោះគុណៈ បានរីករាយតបនឹងព្រះបាទវិទេហៈ ដែលទ្រង់ត្រេកអរក្នុងវិន័យដោយពាក្យថា ៖

"បពិត្រមហារាជ អាត្មាភាពល្មមញុំាងសរីរៈ[២៥]ឲ្យប្រព្រឹត្តទៅបាន រីឯអាការៈរោគក្នុងសរីរៈនិងឥរិយាបថ បញ្ហាទាំងពីរនេះដែលព្រះអង្គត្រាស់សួរហើយនោះ ក៏ស្រួលដែរ" ។ បពិត្រព្រះបាទ

---

[២៣] អត្តភាព, រូប, រាងកាយ, ខ្លួនប្រាណ; សាកសព; រាងខ្ទីង : ថៃទាំសរីរៈ; រម្ងាយសរីរៈ ។ បើរៀងពីខាងដើមសព្ទដទៃសរសេរជា សរីរ អ. ថ. សៈរ៉ីរៈ, ដូចជា សរីរកាយ រាងកាយទាំងមូល, គ្រោងរូប ។

[២៤] ជំងឺ : មានអាពាធ (ប្រើចំពោះតែបព្វជិតនិងគ្រហស្ថជាឥស្សរជនក្រៅពីក្សត្រិយ៍; ចំពោះក្សត្រិយ៍ ប្រើពាក្យថា ប្រឈួន)។ ខ្មែរប្រើជា កិ. ក៏មាន "ឈឺ" : ព្រះតេជព្រះគុណអាពាធបីថ្ងៃហើយ ។

[២៥] អត្តភាព, រូបរាងកាយ, ខ្លួនប្រាណ; សាកសព; រាងខ្ទីង : ថៃទាំសរីរៈ;។

វិទេហៈ បច្ចន្តគ្រាម[២៦] ទាំងឡាយរបស់ព្រះអង្គមិនបះបោរទេឬ? យានរបស់ព្រះអង្គមិនខូចខាតទេឬ? វាហនៈនៅប្រព្រឹត្តទៅបានទេឬ? ព្យាធិទាំងឡាយដែលបៀតបៀនបណ្ដាលឲ្យក្ដៅក្រហល់ក្រហាយក្នុងសរីរៈរបស់ព្រះអង្គមិនមានទេឬ?"

លំដាប់នោះ ព្រះរាជាមានព្រះវរកាយនិងយសដ៏ប្រសើរក្នុងរថ ទ្រង់ប្រាថ្នាធម៌ ក៏រាក់ទាក់រីករាយតប ទើបសួរអត្ថផង ធម៌ផង ហេតុដែលគួរដឹងផងថា ៖

"បពិត្រកស្សបគោត្រ តើសត្វគប្បីប្រព្រឹត្តធម៌ក្នុងមាតាបិតា ដូចម្ដេច? តើគប្បីប្រព្រឹត្តក្នុងអាចារ្យដូចម្ដេច? តើគប្បីប្រព្រឹត្តក្នុងកូននិងប្រពន្ធដូចម្ដេច? តើគប្បីប្រព្រឹត្តក្នុងពួកមនុស្សចាស់ដូចម្ដេច? ក្នុងសមណព្រាហ្មណ៍[២៧] ដូចម្ដេច? ក្នុងពួកពលដូចម្ដេច?

---

[២៦] ស្រុកនៅចុងដែន, ស្រុកនៅជិតព្រំប្រទល់ដែន (ចុងស្រុក; ព. សា. ស្រុកចុងកាត់មាត់ញក) ។

[២៧] សមណៈ និងព្រាហ្មណ៍ អ្នកមានចិត្តស្ងប់ឬអ្នកអនុវត្តធម៌ដើម្បីឈានទៅរកសេចក្ដីស្ងប់ ។ខាងលទ្ធិពុទ្ធសាសនា ហៅព្រះអរហន្តថា ព្រាហ្មណ៍ សំដៅសេចក្ដីថា អ្នកបន្សាត់បាប ឬកម្ចាត់កិលេសអស់ហើយ ព្រោះព្រះអរហន្តលោកកម្ចាត់កិលេសជ្រះស្រឡះអស់ដោយអរហត្តមគ្គហើយ; ហៅថា ខីណាសវព្រាហ្មណ៍ ក៏បាន ។

តើគប្បីប្រព្រឹត្តក្នុងជនបទ ដូចម្ដេច ? តើសត្វទាំងឡាយប្រព្រឹត្តធម៌ដូចម្ដេច ? លះលោកនេះហើយទៅកាន់សុគតិ សត្វពួកខ្លះឋិតនៅក្នុងអធម៌[២៨] មានក្បាលសំយុងចុះធ្លាក់ទៅកាន់នរក តើដូចម្ដេច ?”

អចេលក៏គុណៈនោះ កាលត្រូវស្ដេចសួរយ៉ាងនេះ មិនយល់នូវចម្លើយដែលព្រះអង្គត្រាស់សួរសោះ ហើយក៏សូមឱកាសអំពីព្រះរាជាថា “សូមទ្រង់ព្រះសណ្ដាប់ចុះ មហាបពិត្រ” ហើយបានសម្ដែងនូវមិច្ឆាវាទ[២៩]របស់ខ្លួន ហាក់ដូចជាយកដំបងវាយគោកំពុងដើរនិងដូចជាបោះសំរាមក្នុងថានបាយ ដូច្នេះថា ៖

“បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់នូវបទដែលពិតមិនឃៀងឃ្លាតរបស់អាត្មាភាពចុះ ។ ផលល្អនិងអាក្រក់របស់បុគ្គលអ្នកប្រព្រឹត្តធម៌មិនមានទេ បពិត្រព្រះសម្មតិទេព បរលោកក៏គ្មានដែរ ព្រោះថាក្នុងលោកនេះ មាននរណាមកពីបរលោក ។

---

[២៨] ដែលពុំមែនធម៌,ដែលខុសធម៌,ក្រៅគន្លងធម៌,ខុសច្បាប់;អាក្រក់,ពុំប្រសើរ : មនុស្សអធម្ម (ប្រើជា អធម៌ ក៏បាន) ។

[២៩] សម្ដីខុស គឺការប្រើវាចាខុសគន្លងមានពោលពាក្យកុហក,ពាក្យញុះញង់ជាដើម ។ ព. ផ្ទ. នឹងពាក្យសម្មាវាទ ។

បពិត្រព្រះសម្មតិទេព មួយទៀត មាតាបិតាមិនមានទេ មាតានឹងមានពីណា បិតានឹងមានពីណា បុគ្គលដែលឈ្មោះថា អាចារ្យមិនមានទេ បុគ្គលណានឹងទូន្មានបុគ្គលដែលទូន្មានមិនបាន ។ សត្វទាំងឡាយមានតុល្យភាពស្មើ ៗ គ្នា សត្វទាំងឡាយ ជាអ្នកគោរពចំពោះបុគ្គលចាស់មិនមានទេ កម្លាំងក្តី ព្យាយាមក្តី ក៏មិនមានដែរ បុរសអ្នកព្យាយាមនឹងមានពីណា ? ព្រោះថា សត្វទាំងឡាយទៀង ដូចទូកតូចចងភ្ជាប់នឹងទូកធំ សត្វរមែងបានរបស់ដែលត្រូវបានផលទានក្នុងបរលោកនោះ នឹងមានពីណា ? បពិត្រព្រះសម្មតិទេព[៣០] ផលទានមិនមានទេ បពិត្រព្រះសម្មតិ-ទេព សេចក្តីព្យាយាម មិនមានអំណាចទេ ទានគឺពួកជនពាលទេតើ បញ្ញត្តមក ពួកបណ្ឌិតចាំតែទទួលយកនូវទាននោះ ពួកជនពាល ជាអ្នកមិនមានអំណាច សម្គាល់ខ្លួនថាជាបណ្ឌិត រមែងឲ្យទានដល់បណ្ឌិតទាំងឡាយ" ។

---

[៣០] ទេពតាដោយសន្មតិ គឺមនុស្សដែលគេសន្មតទុកដូចជាទេវតារបស់មនុស្ស (ក្សត្រិយ៍ទ្រង់រាជ្យ) : បពិត្រព្រះសម្មតិទេព, សូមទ្រង់មានព្រះជន្មាយុយឺនយូរក្រៃលែងជាងរយវស្សា ។

លុះនិយាយថាទានឥតផលយ៉ាងនេះហើយ តទៅអចេលក៏នោះបាននិយាយដូច្នេះ ដើម្បីពណ៌នាបាបឥតផលម្តងថា ៖

"ភ្លើង ដី ទឹក ខ្យល់ សុខ ទុក្ខ និងជីវិតទាំង ៧ នេះឈ្មោះថា ពួកទៀង ជាសភាវៈឲ្យដាច់មិនបាន ឲ្យកម្រើកមិនបាន ។ ពួកទៀងទាំង ៧ នេះ គប្បីរស់នៅជាដរាប ដែលបុគ្គលកាត់ហើយមិនឈ្មោះថាកាត់ បុគ្គលអ្នកសម្លាប់ក្តី បុគ្គលអ្នកកាត់ក្តី មិនមានអ្នកណាឈ្មោះថា សម្លាប់អ្នកណាបាន ។ គ្រឿងសស្ត្រាទាំងឡាយគ្រាន់តែចូលទៅក្នុងចន្លោះនៃពួកទៀងប៉ុណ្ណោះ បុគ្គលណាយកដាវដែលសំលៀងហើយ កាត់ក្បាលជនដទៃ បុគ្គលនោះមិនឈ្មោះថាកាត់ពួកទៀងទាំងនោះទេ ផលនៃបាបក្នុងការកាត់នោះនឹងមានពីណា ។ សត្វទាំងអស់ កាលអន្ទោល[៣១]អស់មហាកប្ប[៣២]

---

៣១ គ្រវី; គ្រវែង; ស្ទុះ; លឿន; លឿនដោយកម្លាំងខ្យល់") ត្រាច់រង្គាត់កើតស្លាប់ ក្នុងវាលវដ្តសង្សារ, វិលកើតវិលស្លាប់ : អន្ទោលកើតស្លាប់, អន្ទោលទៅក្នុងភពតូចភពធំ, អន្ទោលជាតិ ។ តាមស្វះស្វែងរកមិនលែង : អន្ទោលរកសព្វទិសទីក៏រកពុំឃើញ ។ (ព.កា.) : សព្វសត្វក្នុងលោក សុទ្ធតែវិយោគ ព្រោះការអន្ទោល មានក្តីនិរាស ព្រាត់ប្រាសជាគោល ទោះបង់រត់ចោល ក៏គ្រាន់តែបង់ ។ រីព្រះសម្ពុទ្ធ មានញាណមោះមុត បំពេញបំណង ដោយទ្រង់យាត្រា តាមមាគ៌ាត្រង់ ពីព្រោះព្រះអង្គ ជ្រាបការអន្ទោល ។

៣២ កប្បមាន ៤ យ៉ាង

៨៤ ទើបបរិសុទ្ធឯង កាលបើមិនទាន់ដល់កាលនោះ បុគ្គល ទោះបីខំប្រឹងសង្រួមយ៉ាងណា ក៏មិនបាននូវភាពបរិសុទ្ធដែរ ។ កាលបើមិនទាន់ដល់កំណត់នោះ ពួកសត្វសូម្បីប្រព្រឹត្តល្អច្រើន ក៏មិនបរិសុទ្ធ ទុកជាធ្វើបាបច្រើន ក៏មិនកន្លងហួសនូវខណៈនោះដែរ ។ សេចក្តីបរិសុទ្ធនៃយើងទាំងឡាយ តាមលំដាប់នៃកប្ប ៨៤ យើងទាំងឡាយមិនកន្លងហួសកម្រិតដ៏ទៀងនោះទេ ដូចសាគរមិនកន្លងហួសច្រាំង" ។

## យោបល់អលាតសេនាបតី

សរុបមកថា អចេលក៏គុណៈនោះ ជាមនុស្សឧច្ឆេទវាទ[៣៣] បាន សម្តែងនូវយោបល់ផ្ទាល់ខ្លួន ដោយសេចក្តីព្យាយាមរបស់ខ្លួន ដោយ

---

១. អាយុកប្ប កាលកំណត់នៃការអស់អាយុរបស់ពពួកមនុស្ស

២. អន្តរកប្ប កាលកំណត់នៃមនុស្សដែលមានអាយុ ១ អសង្ខេយ្យឆ្នាំ ក្នុងអំឡុង ១០០ ឆ្នាំ អាយុត្រូវថយចុះមក ១ ឆ្នាំ រហូតនៅសល់តែអាយុ ១០ ឆ្នាំស្លាប់ រួចហើយក្នុងអំឡុង ១០០ ឆ្នាំ កើនឡើងអាយុ ១ ឆ្នាំ កើនរហូតដល់អាយុ ១ អសង្ខេយ្យវិញ

៣. អសង្ខេយ្យកប្ប ស្មើនឹង ៦៤ អន្តរកប្ប

៤. មហាកប្ប ស្មើនឹង ៤ អសង្ខេយ្យកប្ប ឬស្មើនឹង ២៥៦អន្តរកប្ប ។

[៣៣] អ្នកពោលថាសត្វស្លាប់ហើយសូន្យ មិនកើតទៀត ។

ឥតព្រំដែន ។ អលាតសេនាបតី លុះស្តាប់ពាក្យអចេលក៏ជាកស្សប-គោត្រ ហើយក៏ពោលដូច្នេះថា ៖

"លោកដ៏ចម្រើនពោលយ៉ាងណា ពាក្យនោះពេញចិត្តខ្ញុំដែរ ។ ខ្ញុំរលឹកជាតិរបស់ខ្លួនក្នុងកាលមុន ដែលអន្ទោលទៅហើយថា ក្នុងកាលមុន ខ្ញុំកើតជាមនុស្សប្រព្រឹត្តអាក្រក់ ឈ្មោះបិង្គលៈ ជាអ្នកសម្លាប់គោ ។ ខ្ញុំបានធ្វើបាបដ៏ច្រើន ក្នុងក្រុងពារាណសី ជាក្រុងសម្បូរ ខ្ញុំបានសម្លាប់សត្វដ៏ច្រើន គឺក្របី ជ្រូក ពពែ ។ លុះខ្ញុំច្យុតចាកអត្តភាព[៣៤] នោះ ក៏បានមកកើតក្នុងត្រកូលសេនាបតី ដ៏ស្តុកស្តម្ភ[៣៥] ក្នុងទីនេះ ផលបាបរបស់ខ្ញុំមិនមានពិត ទើបបានជាខ្ញុំមិនទៅកើតក្នុងនរក" ។

**យោបល់ទាសៈឈ្មោះវីជកៈ**

គ្រានោះ ក្នុងក្រុងមិថិលា មានបុគ្គលកម្សត់ម្នាក់ជាទាសៈឈ្មោះវីជកៈ រក្សាឧបោសថហើយ ចូលទៅកាន់សម្នាក់នៃអចេលក៏ឈ្មោះគុណៈ ។ វីជកៈលុះស្តាប់ពាក្យរបស់គុណៈ ជាកស្សបគោត្រ និងពាក្យ

---

[៣៤] អត្តភាព ភាវៈរបស់ខ្លួន;ខ្លួនទាំងមូល;ធម្មតារបស់ខ្លួន;និស្ស័យនៃខ្លួន; អាត្មាភាព ។

[៣៥] អ្នកមានស្តុក អ្នកមានទ្រព្យច្រើន ។

ដែលអលាតសេនាបតីពោលហើយ ក៏ដកដង្ហើមចេញដ៏ក្ដៅរឿយ ៗ យំបង្ហូរទឹកភ្នែក ។ ព្រះបាទវិទេហៈ ទ្រង់ត្រាស់សួរវីជកៈនោះថា ៖

"ម្នាលសម្លាញ់ អ្នកយំរឿងអ្វី ? អ្នកបានឮ ឬបានឃើញអ្វី ? អ្នកដល់នូវទុក្ខវេទនាដូចម្ដេច ? ចូរប្រាប់ឲ្យយើងដឹងផង ?"

វីជកៈបានស្ដាប់ព្រះបន្ទូលព្រះបាទវិទេហៈហើយ ក្រាបបង្គំទូលថា ៖

"បពិត្រមហារាជ ទុក្ខវេទនារបស់ទូលព្រះបង្គំ មិនមានទេ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ចុះ ។ ទូលព្រះបង្គំរលឹកឃើញនូវសេចក្ដីសុខរបស់ទូលព្រះបង្គំ ក្នុងជាតិមុន កាលដែលបានកើតជាសេដ្ឋី ជាអ្នកត្រេកអរក្នុងគុណធម៌ ក្នុងបុរីឈ្មោះ សាកេត ។ ទូលព្រះបង្គំ ត្រូវពួកព្រាហ្មណ៍និងគហបតី[៣៦]សរសើរហើយថា ជាអ្នកត្រេកអរក្នុងការចែករំលែកទាន ជាអ្នកមានការងារដ៏ស្អាត តែទូលព្រះបង្គំ មិនហ៊ាននឹកនានូវអំពើអាក្រក់របស់ខ្លួនដែលធ្វើហើយទេ ។ បពិត្រព្រះបាទវិទេហៈ ទូលព្រះបង្គំលុះច្យុត[៣៧]ចាក

[៣៦] បុរសជាម្ចាស់ផ្ទះ; អ្នកមានធនធានស្ដុកស្ដម្ភ; ពាណិជដែលមានភោគសម្បត្តិច្រើន; សេដ្ឋី ។ ឥត្ថី. គហបតានី ។

[៣៧] ដំណើរដែលឃ្លាតចាកជីវិត គឺសេចក្ដីស្លាប់ ។

អត្តភាព[៣៨]នោះ ក៏មកកើតក្នុងគភ៌[៣៩]នៃកុម្ភទាសី ជាស្រីទុគ៌ត[៤០] ក្នុងក្រុងមិថិលានេះ តាំងពីកើតមក ទូលព្រះបង្គំទុគ៌តក្រៃពេក ។ សូម្បីទូលព្រះបង្គំទុគ៌តយ៉ាងនេះ ក៏តាំងនៅក្នុងការប្រព្រឹត្តស្មើ[៤១] តែងឲ្យភត្តពាក់កណ្ដាលដល់បុគ្គលអ្នកត្រូវការ, តែងរក្សាឧបោសថ អស់ថ្ងៃទី ១៤ និងថ្ងៃទី ១៥ សព្វ ៗ កាល ទាំងមិនបៀតបៀនសត្វផង បានវៀរបង់ការលួចលាក់ឆក់ប្លន់ផង ។ អំពើដែលសន្សំល្អហើយទាំងអស់នេះ មិនមានប្រយោជន៍ទេ ដូចជាអលាតសេនាបតីពោលដែរ ។ ដែលទូលព្រះបង្គំ ទទួលទុក្ខទោសដោយជាក់ស្ដែងនេះ ដូចជាអ្នកលេងដែលមិនមានសិល្បៈ ឬដូច

---

[៣៨] ភារៈរបស់ខ្លួន; ខ្លួនទាំងមូល; ធម្មតារបស់ខ្លួន; និស្ស័យនៃខ្លួន;ស្លាប់ចោលរូបរាងកាយ ចិត្តវិញ្ញាណនេះទៅ ឲ្យឈ្មោះថា ច្យុតចាកអត្តភាពនេះទៅ ។

[៣៩] សត្វកើតក្នុងផ្ទៃ : ទ្រង់គភ៌, ស្រីមានគភ៌ ពាក្យធម្មតាហៅថា មានផ្ទៃ, មានផ្ទៃពោះ, ទម្ងន់, ជាដើម ។

[៤០] ដែលដល់នូវសេចក្ដីលំបាកគឺដែលទ័លក្រ, ដែលក្រីក្រទ្រព្យ, ដែលខ្សត់ទ្រព្យ : មនុស្សទុគ៌ត ។

[៤១] ប្រព្រឹត្តតាមធម្មតាដូចកាលពីមុន គឺពីមុនធ្លាប់ធ្វើយ៉ាងណា ក៏ប្រព្រឹត្តបន្តទៀត មិនឲ្យអាក់ខាន បើពីមុនធ្លាប់ឲ្យទាន ក៏នៅតែឲ្យទានបន្ត ធ្លាប់រក្សាសីល ក៏នៅតែរក្សាសីលបន្តរហូត ។

ជាអលាតសេនាបតីជាអ្នកលេងស្កា[៤២]បានរៀនហើយ ក៏បានទទួលជ័យជម្នះ ទូលព្រះបង្គំមិនឃើញទ្វារសម្រាប់ទៅសុគតិសោះ បពិត្រព្រះរាជា ព្រោះហេតុនោះ បានជាទូលព្រះបង្គំយំទួញ ព្រោះបានស្តាប់ភាសិតនៃអចេលក៍ ជាកស្សបគោត្រ" ។

ព្រះរាជាព្រះនាមអង្គតិ ទ្រង់ព្រះសណ្តាប់ពាក្យវីជកៈហើយ ទ្រង់ត្រាស់ថា ៖

"ម្នាលវីជកៈ ទ្វារនៃសុគតិ[៤៣]មិនមានទេ អ្នកចូរសង្ឃឹមការដ៏ទៀងចុះ ។ បានឮថា សុខឬទុក្ខ ជារបស់ទៀង ដែលពួកសត្វតែងបានសេចក្តីបរិសុទ្ធិ ព្រោះសង្សាររបស់សត្វទាំងអស់ រមែងមាន ចូរអ្នកកុំប្រញាប់ចង់ឃើញ ក្នុងកាលដែលមិនទាន់ដល់កំណត់នោះឡើយ ។ ក្នុងកាលមុន យើងជាបុគ្គលល្អ បានខ្វល់ខ្វាយបម្រើនូវ

---

[៤២] ឈ្មោះល្បែងមួយប្រភេទ ពួកចត្រង្គ តែមានមេពីរ ហៅកាត់ថា តៅ មានសណ្ឋាន ៤ ជ្រុង មានរន្ធ ៦ សម្រាប់លើកទម្លាក់លើក្តារ, មានកូន ២៤ ឬ ៣០ ... ។ ហៅ បាសកា ឬ បាស្កា ក៏បាន ។

[៤៣] ដំណើរល្អ, ការទៅដោយល្អ (ចំពោះការស្លាប់កើត); ការប្រព្រឹត្តត្រូវផ្លូវ, ត្រូវគន្លងធម៌; គន្លងឬលំអានយុត្តិធម៌ ។ ឋានសួគ៌ : ស្លាប់ទៅកើតក្នុងសុគតិ ។

ពួកព្រាហ្មណ៍ និងគហបតី[៤៤] កាលប្រៀនប្រដៅនូវវោហាររាជកិច្ច ក៏សាបសូន្យចាកសេចក្ដីត្រេកអរក្នុងកាមគុណ[៤៥]ជាលំដាប់" ។

លុះពោលយ៉ាងនេះហើយ ព្រះរាជាត្រាស់ថា ៖

"បពិត្រកស្សបៈដ៏ចម្រើន យើងធ្វេសប្រហែសអស់កាលប៉ុណ្ណោះហើយ ប៉ុន្តែឥឡូវនេះ យើងបានលោកជាអាចារ្យ តាំងពីគ្រានេះទៅ យើងនឹងសោយតម្រេកត្រេកត្រអាលក្នុងកាមតែម៉្យាង ការស្ដាប់ធម៌របស់លោកមកប៉ុណ្ណោះឃើញថាសមល្មមហើយសម្រាប់យើង ការស្ដាប់បន្តទៀតវាជាការយឺតយូរណាស់ ឥឡូវនេះ យើងឈប់ស្ដាប់បុណ្ណឹងសិនចុះ ព្រោះយើងមាន ព្រះរាជកិច្ច[៤៦]ជាច្រើន និងមានដំណើរត្រូវយាងចេញទៅទៀត" ។

រួចទ្រង់ត្រាស់នឹងអចេលក៏ជាកស្សបគោត្រថា ៖

---

[៤៤] (គហ "ផ្ទះ" + បតិ "ម្ចាស់; មេ; ចៅហ្វាយ"; គួហបតិ) បុរសជាម្ចាស់ផ្ទះ; អ្នកមានធនធានស្ដុកស្ដម្ភ; ពាណិជដែលមានភោគសម្បត្តិច្រើន; សេដ្ឋី ។ ឥត្ថី. គហបតានី ។

[៤៥] ការយល់ថាកាមមានគុណ កាមមានប្រយោជន៍ សម្គាល់ថាកាមមានសេចក្ដីសុខ

[៤៦] កិច្ចឬក្រឹត្យរបស់ព្រះរាជា; កិច្ចការផែនដី (ក្នុងកម្ពុជរដ្ឋសព្វថ្ងៃប្រើពាក្យនេះជាឈ្មោះសៀវភៅ ដែលប្រាប់អំពីដំណើរកិច្ចការរាជការផ្សេងៗ : សៀវភៅរាជកិច្ច) ។

"បពិត្រលោកដ៏ចម្រើន ប្រសិនបើមានការប្រជុំ យើងនឹងជួបគ្នាម្តងទៀត" ។

# ជំពូកទី ២

## ស្តេចអង្គតិប្រកាន់ទស្សនៈខុស

### ព្រះបាទវិទេហៈលះបង់រាជកិច្ច

*ព្រះបាទវិទេហៈ ទ្រង់ត្រាស់ព្រះតម្រាស់នេះហើយ ទ្រង់យាង ឡើងរថ ត្រឡប់ទៅកាន់ព្រះរាជនិវេសន៍ ឡើងកាន់ផ្ទៃប្រាសាទវិមាន ចន្ទក៍របស់ព្រះអង្គវិញ ។*

*ព្រះរាជា យាងទៅកាន់សម្នាក់អចេលក៍ឈ្មោះ គុណៈដំបូង ថ្វាយបង្គំគុណៈនោះ រួចសួរបញ្ហា ។ ប៉ុន្តែកាលយាងមកវិញ មិនថ្វាយ បង្គំលាទេ យាងមកតែម្តង ។ អចេលក៍ឈ្មោះ គុណៈមិនបានទទួល លាភសក្ការៈអ្វីពីព្រះរាជា ដោយហោចទៅសូម្បីត្រឹមតែកិរិយាថ្វាយ បង្គំក៏អត់ទៅហើយ កុំបាច់និយាយឡើយដល់គ្រឿងសក្ការៈពិសេស ៗ មានដុំបាយជាដើម នឹងបានដូចម្តេចទៅព្រោះភាពនៃខ្លួនជាបុគ្គល គ្មានគុណធម៌ ។ ព្រឹកឡើង ព្រះរាជាទ្រង់កោះប្រជុំមន្ត្រីទាំងឡាយមក ហើយត្រាស់ប្រាប់ថា ៖*

"អ្នកទាំងឡាយចូរទំនុកបម្រុង កាមគុណទាំងឡាយដល់យើង ពីគ្រានេះទៅ យើងនឹងសោយសុខក្នុងកាមគុណតែម្យ៉ាងប៉ុណ្ណោះ ចូរអាមាត្យទាំងឡាយចាត់ចែងកាមទាំងឡាយ ក្នុងវិមានចន្ទក៍របស់យើងសព្វ ៗ កាល នាកាលសេចក្ដីកំបាំង និងសេចក្ដីជាក់ស្ដែងកើតឡើង អាមាត្យឯណានីមួយ កុំមករកយើងឡើយ ។ អាមាត្យឈ្មោះ វិជយៈ ១ ឈ្មោះសុនាមៈ ១ អលាតសេនាបតី ១ ទាំង ៣ នេះ ជាអ្នកឈ្លាសវៃក្នុងវោហាររាជកិច្ច ចូរអង្គុយក្នុងទីជាទីវិនិច្ឆ័យសេចក្ដីនេះចុះ ។ កិច្ចការផ្សេង ៗ មិនចាំបាច់ប្រាប់យើងទេ ហ៏មន្ត្រីនេះ ហ៏មន្ត្រីនោះ ចូរធ្វើកិច្ចវិនិច្ឆ័យចុះ" ។

ព្រះបាទវិទេហៈ លុះទ្រង់ត្រាស់រួចហើយ ក៏សោយសេពកាមទាំងឡាយដ៏ច្រើន វង្វេងជ្រប់ងប់ងុល តម្រេកក្នុងកាមយ៉ាងខ្លាំង ឈប់ខ្វល់ខ្វាយចំពោះព្រាហ្មណ៍ គហបតី និងរាជកិច្ចផ្សេង ៗ ទាំងអស់ ។

## ព្រះរាជធីតារុចាចូលគាល់ព្រះបិតា

តាំងពីកាលនោះមក រហូតដល់រាត្រី ១៤ នាងរាជកញ្ញារបស់ព្រះបាទវិទេហៈ ព្រះនាមរុចាជាធីតា[៤៧]បង្កើត ជាទីស្រឡាញ់បានពោលចំពោះមេនំ[៤៨]ថា ៖

"បពិត្រម៉ែ សូមម៉ែប្រដាប់ស្អិតស្អាងព្រះកាយខ្ញុំ ទាំងពួកស្ត្រីជាសម្លាញ់របស់ខ្ញុំ ក៏ចូរប្រដាប់ស្អិតស្អាងដែរ ស្អែកជាថ្ងៃទី ១៥ ជាថ្ងៃទិព្វ ខ្ញុំនឹងទៅកាន់សម្នាក់បិតារបស់ខ្ញុំ" ។

ស្ត្រីទាំងឡាយបាននាំមកនូវផ្កាកម្រង ខ្លឹមចន្ទន៍[៤៩] កែវមណី[៥០] ស័ង្ខ[៥១] កែវមុក្តា[៥២] មានតម្លៃដ៏ច្រើននិងសំពត់កម្ពល[៥៣]ពណ៌ក្រហមផ្សេង ៗ

---

[៤៧] កូនស្រី : ធីតាខ្ញុំមានព្យាយាមរៀនណាស់ ។

[៤៨] ស្ត្រីអ្នកទទួលភារៈបំបៅដោះកូនតូចជាជំនួសម្ដាយបង្កើត។

[៤៩] ឈ្មោះឈើមានខ្លឹមក្រអូប : ចន្ទន៍ស, ចន្ទន៍ក្រហម ។

[៥០] ឈ្មោះកែវ ឬ ត្បូងវិសេសមួយប្រភេទ;ពេជ្រ,ខ្យងដាំ;ច្រើននិយាយថា កែវមណី ។

[៥១] ខ្យងសមុទ្រមួយបែប គូទស្រួចមានស្នាមវិលស្រួល សម្បុរ-ស, សម្រាប់ពួកបារគូផ្លុំ ឬសម្រាប់ដងទឹកសក្តិសិទ្ធិស្រោចក្នុងព្រះរាជពិធីជាដើម : ពួកបារគូផ្លុំស័ង្ខ, ស្រោចទឹកក្ងស់ទឹកស័ង្ខថ្វាយ ។ ឈ្មោះសារាយសមុទ្រមួយប្រភេទដើមល្អិតល្វន់សម្បុរ-ស : សារាយស័ង្ខ (ហៅ សារាយអំបោះ ក៏បាន) ។

ថ្វាយព្រះរាជកញ្ញានោះ ។ ពួកស្ត្រីដ៏ច្រើន បានចោមរោមព្រះរាជកញ្ញា ព្រះនាមរុចានោះ ដែលមានសម្បុរដ៏រុងរឿង កំពុងគង់លើតាំងជាវិការៈនៃមាស ។

ឯនាងរុចានោះ ស្អិតស្អាងដោយគ្រឿងអាភរណៈទាំងពួងឋិតនៅក្នុងកណ្ដាលនៃពួកស្ត្រីជាសម្លាញ់ បានចូលទៅកាន់វិមានចន្ទក៍[៥៤]ដូចជាផ្លេកបន្ទោរអាស្រ័យមេឃ ។ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះបាទវិទេហៈ ដែលទ្រង់ត្រេកអរក្នុងវិន័យ ហើយយាងចូលទៅគង់លើតាំង ដែលវិចិត្រដោយមាស ក្នុងទីសមគួរ ។

ព្រះបាទវិទេហៈ ទ្រង់ទតឃើញការប្រជុំនោះ ដូចជាទីប្រជុំពួកស្ត្រីទេពអប្សរ ទើបត្រាស់ព្រះតម្រាស់នេះនឹងរុចា ដែលឋិតនៅត្រង់កណ្ដាលនៃពួកស្ត្រីជាសម្លាញ់ថា ៖

---

[៥២] ឈ្មោះកែវ ឬត្បូងមានតម្លៃមួយប្រភេទ; ត្បូងដែលកើតអំពីខ្យង, គជ់ខ្យង; ខ្យងដាំ : កែវមុក្តា ។

[៥៣] ឈ្មោះសំពត់វិសេសមួយប្រភេទ ដែលធ្វើដោយរោមសត្វ.... ។

[៥៤] ប្រាសាទដ៏ល្អវិសេសសម្រាប់ព្រះមហាក្សត្រ ច្រើនសាងនៅខាងមុខគេ

"នាងត្រេកអរក្នុងប្រាសាទស្រះបោក្ខរណីខាងក្នុងដែរឬ? ពួកជនបាននាំបង្អែមមកមានប្រការដ៏ច្រើនប្រការ ដល់នាងសព្វកាលដែរឬទេ? នាងទាំងឡាយជាកុមារី បានក្រងកម្រងផ្កាដ៏ច្រើន ជាស្ត្រីនៅលេងល្បែង ត្រេកអរដោយសេចក្ដីសប្បាយ បានធ្វើផ្ទះតូច ៗ ទាំងឡាយផ្សេង ៗ គ្នាខ្លះដែរឬ? មួយទៀត នាងខ្វះខាតដោយវត្ថុអ្វី ជនទាំងឡាយបាននាំមកឲ្យនាងឆាប់ដែរឬ? ម្នាលនាងមានកត្រួផាត់លាបលនល្អ នាងចូរធ្វើតាមចិត្តចុះ សូម្បីរបស់ស្មើដោយព្រះចន្ទ ក៏ឪពុកផ្ដល់ឲ្យនាងបានដែរ" ។

នាងរុចា បានស្ដាប់ព្រះរាជឱង្ការ[៥៥]ព្រះបាទវិទេហៈហើយ ទូលតបព្រះបិតាថា ៖

[៥៥] ខ្មែរក្នុងបុរាណសម័យ, កាលដែលកំពុងប្រតិបត្តិជឿកាន់តាមលទ្ធិព្រាហ្មណ៍, ប្រើពាក្យនេះជាជំនួសព្រះបរមនាមនៃព្រះមហាក្សត្រថា ព្រះរាជឱង្ការ សំដៅសេចក្ដីថា "ព្រះរាជា ឬព្រះករុណាជាអម្ចាស់ជីវិតលើត្បូង" (មិនចេញឲ្យចំព្រះបរមនាម) : ព្រះបាទសម្ដេចព្រះរាជឱង្ការបរមបពិត្រក្រុងកម្ពុជាធិបតី... ។ លុះចំណេរកាលតៗមក ខ្មែរប្រើពាក្យនេះជាព្រះរាជតម្រាស់នៃព្រះមហាក្សត្រថា ព្រះឱង្ការ ឬ ព្រះរាជឱង្ការ, ព្រះបរមរាជឱង្ការ ប្រើជាប់រៀងដរាបមកដល់សម័យបច្ចុប្បន្ននេះ ។ ឱង្ការព្រះ ព្រះបន្ទូលព្រះ គឺពុទ្ធវចនៈ ឬពុទ្ធភាសិត ។

"បពិត្រមហារាជ របស់ទាំងអស់នុ៎ះ ខ្ញុំម្ចាស់តែងបានក្នុងសម្នាក់របស់ព្រះអង្គជាឥស្សរៈ ។ ស្អែកជាថ្ងៃទី ១៥ ជាថ្ងៃទិព្វ សូមឲ្យពួកជននាំកហាបណៈ ១.០០០ ដល់ខ្ញុំម្ចាស់ ៗ នឹងឲ្យទានចំពោះអ្នកដំណើរទាំងអស់ តាមទំនងដែលខ្ញុំម្ចាស់ធ្លាប់ឲ្យហើយ" ។

ព្រះបាទអង្គតិ ទ្រង់ព្រះសណ្ដាប់ពាក្យនាងរុចាហើយ ទ្រង់ត្រាស់ថា ៖

ពហុំ វិនាសិតំ វិត្តំ និរត្ថំ អជលំ តយា។
ឧបោសថេ វសំ និច្ចំ អន្នបានំ ន កុញ្ជសិ
និយតេតំ អភុត្តព្វំ នត្ថិ បុញ្ញំ អភុញ្ជតោ ។

"ទ្រព្យដ៏ច្រើនឈ្មោះថានាងធ្វើឲ្យវិនាស ធ្វើឲ្យឥតប្រយោជន៍ ធ្វើឲ្យឥតផលហើយ ។ នាងរក្សាឧបោសថ មិនបរិភោគបាយទឹកជានិច្ច ឯបាយនិងទឹកដែលនាងមិនបរិភោគនេះ ជារបស់ទៀងបុណ្យមិនមានដល់បុគ្គលបរិភោគផង អ្នកមិនបរិភោគផង" ។

មែនពិត សត្វទាំងឡាយកន្លងហួសមហាកប្ប ៨៤ ទៅ គង់តែបរិសុទ្ធឯង ។ ដូចយ៉ាងទាសៈឈ្មោះវីជកៈបានស្ដាប់ភាសិតរបស់អចេលក៍ ជាកស្សបគោត្រ ក្នុងកាលនោះ ក៏ដកដង្ហើមចេញដ៏ក្ដៅរឿយៗ យំសម្រក់ទឹកភ្នែក ។ ម្នាលនាងរុចា នាងកាលរស់នៅ ជរាបណា កុំអត់បាយ

ឡើយ ។ ម្នាលនាងដ៏ចម្រើន បរលោក[៥៦]មិនមានទេ ។ ព្រោះហេតុអ្វី នាងប្រឹងឲ្យលំបាកឥតប្រយោជន៍ ?

ព្រះរាជាបាននាំមកនូវរឿងវីជកៈ ដើម្បីធ្វើជាឧទាហរណ៍ដល់នាងរុចាដែរថា ៖

"សូម្បីវីជកៈ កាលពីអតីតជាតិ គាត់បានធ្វើកល្យាណកម្ម[៥៧] ហើយកើតក្នុងផ្ទៃទាសី ដោយអានិសង្សនៃកល្យាណកម្មនោះ ។ គុណាចារ្យពោលដូច្នេះថា លោកនេះមិនមាន, លោកដទៃមិនមាន មាតាមិនមាន, បិតាមិនមាន, សត្វទាំងឡាយជាឱបបាតិក[៥៨] កំណើតមិនមាន, សមណព្រាហ្មណ៍អ្នកស្មោះត្រង់ បដិបត្តិត្រឹមត្រូវក្នុងលោកមិនមាន ។ មែនពិត កាលបើលោកដទៃមាន សូម្បី

---

[៥៦] លោកឯមុខ : ទៅកាន់បរលោកហើយ គឺធ្វើមរណកាលទៅកាន់លោកឯខាងមុខហើយ ។ ព. ផ្ទ. ឥធលោក ។

[៥៧] ន. អំពើល្អ, កុសលកម្ម ។ ព. ផ្ទ. លាមកកម្ម ។

[៥៨] ដែលកើតឯង; សត្វដែលចាប់កំណើតឯងៗ : កំណើតឧបបាតិក (ហៅ ឧបបាតិកជាតិ ឬ ឧបបាតិកកំណើត ក៏បាន) ។ ឧបបាតិកសត្ត ឬ ឱប-- សត្វដែលឧប្បត្តិកកើតឯង ដោយអំណាចកម្លាំងកុសលឬអកុសលបណ្ដាលឲ្យកើត (ឥតមាតាបិតា, ឥតមេឥតបា) : ទេវតាពួកខ្លះនិងសត្វនរកជាដើមជាឧបបាតិកសត្ត ។

លោកនេះក៏ឈ្មោះថាមាន, តែលោកដទៃនោះ មិនមាន ។ កាលបើមាតាបិតាមាន បុត្រធីតាក៏ឈ្មោះថាមាន តែពួកគាត់មិនមាន។ កាលបើធម៌មាន សមណព្រាហ្មណ៍អ្នកប្រកបដោយធម៌ ក៏ឈ្មោះថាមាន តែពួកគេមិនមាន ។ នាងឲ្យទានធ្វើអ្វី នាងរក្សាសីលធ្វើអ្វី នាងជួបតែអំពើឥតប្រយោជន៍" ។

## ព្រះរាជធីតាបន្ទោសការសេពគប់ពាល

នាងរុចា មានសម្បុរដ៏រុងរឿង បានស្ដាប់ព្រះបន្ទូលរបស់ព្រះបាទវិទេហៈ កាលដឹងធម៌ខាងដើមនិងខាងចុង ទើបពោលពាក្យនេះនឹងបិតាថា ៖

សុតមេវ បុរេ អាសិ   សក្ខិ ទិដ្ឋមិទំ មយា
ពាលូបសេវី យោ ហោតិ ពាលោវ សមបជ្ជថ។

មូឡ្ហោ ហិ មូឡ្ហមាគម្ម   ភិយ្យោ មោហំ និគច្ឆតិ
បតិរូបំ អលាតេន ពីជកេន ច មុយ្ហិតុន្តិ។

"ពីដើម ខ្ញុំម្ចាស់គ្រាន់តែឮ ថ្ងៃនេះ រឿងនេះខ្ញុំម្ចាស់ឃើញជាក់ច្បាស់ហើយថា បុគ្គលណាសេពគប់នឹងជនពាល បុគ្គលនោះទៅជាបុគ្គលពាលដែរ ។ ដ្បិតថា បុគ្គលវង្វេង អាស្រ័យនឹងបុគ្គល

វង្វេង រមែងរឹងរឹតតែសេចក្ដីវង្វេងខ្លាំងឡើង អាលាតសេនាបតី និងទាសៈឈ្មោះវីជកៈគួរវង្វេងទៅចុះ តែព្រះអង្គកុំវង្វេងឡើយ”។

លុះរិះគន់ជនទាំងពីរនាក់យ៉ាងនេះហើយ ព្រះនាងរុចាហេតុតែចង់ដោះបិតាឲ្យរួចពីទិដ្ឋិ ក៏បានពោលសរសើរបិតាថា ៖

“ត្វញ្ច ទេវាសិ សប្បញ្ញោ ធីរោ អត្ថស្ស កោវិទោ
កថំ ពាលេភិ សទិសំ ហីនទិដ្ឋឹ ឧបាគមិ។

សចេបិ សំសារបថេន សុជ្ឈតិ និរត្ថិយា បព្វជ្ជាគុណស្ស
កីដោវ អគ្គឹ ជលិតំ អបាបតំ ឧបបជ្ជតិ មោហមូឡ្ហោនគ្គភាវំ។

សំសារសុទ្ធីតិ បុរេ និវិដ្ឋា កម្មំ វិទូសេន្តិ ពហូ អជានំ
បុព្វេ កលី ទុគ្គហិតោវនត្ថា ទុម្មោចយា ពលិសា អម្ពុជោវ។

“បពិត្រព្រះសម្មតិទេព ព្រះអង្គប្រកបដោយបញ្ញា ជាអ្នកប្រាជ្ញឈ្លាសក្នុងសេចក្ដីចម្រើន ហេតុអ្វីព្រះអង្គប្រហែលនឹងពួកជនពាល ហើយលុះក្នុងទិដ្ឋិថោកទាប ? ប្រសិនបើសត្វបរិសុទ្ធដោយគន្លងនៃសំសារ បព្វជ្ជានៃអចេលក៏ឈ្មោះគុណៈ ក៏មិនមានប្រយោជន៍ដែរ អចេលក៏ឈ្មោះគុណៈ ជាអ្នកវង្វេងដោយមោហៈ

ដល់នូវភាពជាអ្នកអាក្រាត ដូចជាសត្វកណ្ដប ទម្លាក់ខ្លួនក្នុងភ្លើងកំពុងឆេះ ។ ជនទាំងឡាយច្រើននាក់ កាលមិនដឹង ត្រូវអចេលក៍ឈ្មោះគុណៈទូន្មានហើយ ក្នុងកាលមុនថា សេចក្ដីបរិសុទ្ធិព្រោះគន្លងនៃសំសារដូច្នេះ ក៏បដិសេធនូវកម្មចេញ ប្រយោជន៍ដែលជនកាន់មិនល្អហើយក្នុងកាលមុនក៏ទៅជាទោសដូចត្រីដែលរួចអំពីសន្ទូច បានដោយក្រ” ។

ព្រះនាងរុចា បាននាំមកនូវឧទាហរណ៍បន្ថែមថា ៖

ឧបមំ តេ ករិស្សាមិ　　មហារាជ តវត្ថិយា
ឧបមាយ មិធេកច្ចេ　　អត្ថំ ជានន្តិ បណ្ឌិតា។

វាណិជានំ យថា នាវា　　អប្បមាណភរា គរុ
អតិភារំ សមាទាយ　　អណ្ណវេ អវសីទតិ។

ឯវមេវ នរោ បាបំ　　ថោកំ ថោកម្បិ អាចិនំ
អតិភារំ សមាទាយ　　និរយេ អវសីទតិ។

ន តាវ ភារោ បរិបូរោ　　អលាតស្ស មហីបតិ
អាចិនាតិ ច តំ បាបំ　　យេន គច្ឆតិ ទុគ្គតិំ។

បុព្ពេវស្ស កតំ បុញ្ញំ អលាតស្ស មហីបតិ
តស្សេវ ទេវ និស្សន្ទោ យញ្ចេសោ លភតេ សុខំ ។

ចិរំ ឋត្វាន តំ បុញ្ញំ គោបាលោ ពហុធនោ អនិស្សរោ
ឧទ្ធមគ្គំ អវហាយ កុម្មគ្គមនុធាវតិ ។

តុលា យថា បគ្គហិតា ឱហិតេ តុលមណ្ឌលេ
ឧន្នមេតិ តុលាសីសំ ភារេ ឱរោបិតេ សតិ ។

ឯវមេវ នរោ បុញ្ញំ ឋោកំ ឋោកម្បិ អាចិនំ;
សគ្គាតិមានោ ទាសោវ ពីជកោ សាតវេ រតោ ។

"បពិត្រមហារាជ ខ្ញុំម្ចាស់នឹងធ្វើឧបមាថ្វាយដល់ព្រះអង្គ ដើម្បីប្រយោជន៍ដល់ព្រះអង្គ ព្រោះថា បណ្ឌិតពួកខ្លះ ក្នុងលោកនេះ រមែងដឹងសេចក្តីដោយពាក្យឧបមា ។ ទូករបស់ពួកឈ្មួញ ផ្ទុកភារៈធ្ងន់ហួសប្រមាណ នាំទៅនូវភារៈធ្ងន់លើសលុប រមែងលិចក្នុងសមុទ្រយ៉ាងណា នរជនកាលសន្សំបាបបន្តិចម្តង ៗ ឈ្មោះថាជាអ្នកកាន់យកនូវភារៈដ៏លើសលុប រមែងលិចចុះក្នុងនរក ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គជាម្ចាស់ផែនដី ភារៈដ៏ធ្ងន់របស់អលាតសេនាបតី មិនទាន់ពេញប្រៀបនៅឡើយ អលាតសេនា-

បតីទៅកាន់ទុគ្គតិ ព្រោះបាបណា គាត់នៅតែសន្សំបាបនោះ ។ បពិត្រព្រះអង្គជាម្ចាស់ផែនដី អលាតសេនាបតី បានធ្វើបុណ្យក្នុងកាលមុន បពិត្រព្រះសម្មតិទេព ឯអលាតសេនាបតីនុ៎ះ បានសុខព្រោះអានិសង្សបុណ្យ ដែលគាត់បានធ្វើហើយក្នុងកាលមុននោះឯង ។ បុណ្យរបស់គាត់នោះអស់ហើយ បានជាគាត់ត្រេកអរក្នុងអកុសលកម្ម លះបង់នូវផ្លូវត្រង់ហើយដើរទៅតាមផ្លូវវៀចវិញ ។ កាលវត្ថុធ្ងន់ ដែលគាត់ដាក់លើថាសនៃជញ្ជីង ជញ្ជីងក៏បះ កាលបើគេដកវត្ថុធ្ងន់ចេញហើយ ក្បាលជញ្ជីងក៏ងើបឡើង យ៉ាងណាមិញ ។ នរជនកាលសន្សំបុណ្យ សូម្បីបន្តិចម្តង ៗ ដូចជាទាសៈឈ្មោះ វីជកៈ កាលប្រាថ្នាឋានសួគ៌ ត្រេកអរក្នុងកុសលកម្មមានផលល្អ ក៏យ៉ាងនោះដែរ ។ ក្នុងកាលអស់នៃបាបកម្មនេះគាត់នឹងកើតក្នុងទេវលោក ដោយសារផលនៃកល្យាណកម្ម ។ ប៉ុន្តែឥឡូវនេះ គាត់ដល់នូវភាពជាទាសៈ ភាពជាទាសៈនោះ មិនមែនដល់ដោយសារផលនៃកល្យាណកម្មទេ ។ មែនពិត បាបកម្មដែលគាត់បានធ្វើពីអតីតជាតិ សម្រាប់ប្រព្រឹត្តទៅដើម្បីភាពជាទាសៈមានពិតប្រាកដ" ។

កាលនឹងបញ្ជាក់សេចក្តីនេះ ព្រះនាងរុចាបានពោលថា ៖

យមជ្ជ ពីជកោ ទាសោ    ទុក្ខំ បស្សតិ អត្តនិ
បុព្វេវស្ស កតំ ចាបំ    តមេសោ បដិសេវតិ។

ទីយតេ ចស្ស តំ ចាបំ    តថា ហិ វិឆយេ រតោ
កស្សបញ្ច សមាបជ្ជ    មា ហេវុប្បថមាគម ។

*"បាបណា ដែលវីជកៈនោះបានធ្វើទុកក្នុងកាលមុន ទាសៈឈ្មោះវីជកៈឃើញទុក្ខណា ចំពោះខ្លួនក្នុងថ្ងៃនេះ ព្រោះគាត់បានធ្វើបាបក្នុងជាតិមុន បានជាគាត់ទទួលទុក្ខនោះ ។ បាបរបស់គាត់នោះអស់ បានជាគាត់ត្រេកអរក្នុងវិន័យ សូមព្រះអង្គកុំគប់រកអចេលក៍ឈ្មោះគុណៈ ជាកស្សបគោត្រ ហើយដើរកាន់ផ្លូវខុសផ្លូវទៅនរកឡើយ សូមព្រះអង្គកុំធ្វើបាបកម្មឡើយ" ។*

*តទៅនេះ ព្រះនាងរុចាបង្ហាញអំពីទោសនៃការគប់រកបាបមិត្រ[៥៩] និងគុណនៃការគប់រកកល្យាណមិត្រ[៦០]ដូច្នេះ ៖*

យំ យញ្ហិ រាជ ភជតិ    សន្តំ វា យទិ វា អសំ

---

*[៥៩] មិត្រអាក្រក់ គឺមិត្រដែលនាំឲ្យខូចប្រយោជន៍, នាំឲ្យមានសេចក្ដីវិនាសផ្សេងៗ : កុំសេពគប់នឹងបាបមិត្រ ។ ព. ផ្ទ. កល្យាណមិត្ត ។ បាបមិត្រ*

*[៦០] មិត្តល្អ,មិត្តត្រឹមត្រូវដែលបុគ្គលគួរសេពគប់ គួររាប់រកយកជាគ្នា ។ ព.ផ្ទ.បាបមិត្ត។*

សីលវន្តំ វិសីលំ វា　　វសំ តស្សេវ គច្ឆតិ។

យាទិសំ កុរុតេ មិត្តំ　　យាទិសំ ចូបសេវតិ;
សោបិ តាទិសកោ ហោតិ　　សហវាសោ ហិ តាទិសោ។

សេវមានោ សេវមានំ　　សម្ផុដ្ឋោ សម្ផុសំ បរំ;
សរោ ទិទ្ធោ កលាបំវ　　អលិត្តមុបលិម្បតិ
ឧបលេបភយា ធីរោ　　នេវ បាបសខា សិយា ។

បូតិមច្ឆំ កុសគ្គេន　　យោ នរោ ឧបនយ្ហតិ
កុសាបិ បូតិ វាយន្តិ　　ឯវំ ពាលូបសេវនា។

តគរញ្ច បលាសេន　　យោ នរោ ឧបនយ្ហតិ
បត្តាបិ សុរភិ វាយន្តិ　　ឯវំ ធីរូបសេវនា។

តស្មា បត្តបុដស្សេវ　　ញត្វា សម្បាកមត្តនោ
អសន្តេ នោបសេវេយ្យ　　សន្តេ សេវេយ្យ បណ្ឌិតោ
អសន្តោ និរយំ នេន្តិ　　សន្តោ បាបេន្តិ សុគ្គតិំ ។

"បពិត្រព្រះរាជា បុគ្គលគប់រកបុគ្គលណា ៗ ជាសប្បុរស[៦១] ឬជាអសប្បុរស[៦២] មានសីលឬមិនមានសីល រមែងលុះនូវអំណាចនៃបុគ្គលនោះ ៗ ឯង ។ បុគ្គលធ្វើបុគ្គលបែបណាឲ្យជាមិត្រផង សេពបុគ្គលបែបណាផង បុគ្គលនោះ រមែងប្រាកដដូចបុគ្គលនោះដែរ ព្រោះថា ការនៅរួមគ្នា រមែងប្រាកដដូច្នោះ ។ អាចារ្យដែលកូនសិស្សពាល់ត្រូវហើយ រមែងប្រឡាក់នូវកូនសិស្សដែលមិនទាន់ប្រឡាក់ ដូចព្រួញលាបថ្នាំពិស ប្រឡាក់បំពង់ព្រួញដូច្នោះ អ្នកប្រាជ្ញមិនត្រូវមានសម្លាញ់ដ៏លាមក[៦៣] ព្រោះខ្លាច

---

[៦១] បុរសអ្នកស្ងប់ គឺមនុស្ស (ប្រុសក្តីស្រីក្តី) អ្នកមិនធ្វើអំពើអាក្រក់ដោយកាយវាចាចិត្ត, អ្នកប្រព្រឹត្តល្អ, អ្នកត្រឹមត្រូវ : ពួកសប្បុរស ។ ខ្មែរប្រើជា គុ. សំដៅសេចក្តីថា "ល្អ, ប្រសើរ, ត្រឹមត្រូវ" ក៏មាន : មានចិត្តសប្បុរស, មានធម៌សប្បុរស, មនុស្សសប្បុរស, ត្រូវប្រើសម្តីសប្បុរសរកគ្នា (ឬប្រើជា ន. ដែរ. សំដៅសេចក្តីថា "ចិត្តសប្បុរស,..."ក៏បាន) ។

[៦២] បុរសអ្នកមិនស្ងប់ គឺបុរសស្ត្រីអ្នកកាន់អំពើអាក្រក់ដោយកាយវាចាចិត្ត; អ្នកមានចិត្តអាក្រក់ : សូមប្រាថ្នាកុំឲ្យចួបប្រទះអសប្បុរស !។ ខ្មែរប្រើជា គុ. ក៏មាន, សំដៅសេចក្តីថា "អាក្រក់; ដែលមានចិត្តអាក្រក់" : ចិត្តអសប្បុរស; មនុស្សអសប្បុរស ។ ព. ផ្ទ. សប្បុរស (ម. ព. អសប្បុរិស ផង) ។

[៦៣] អាក្រក់, ពុំប្រសើរ, ថោកទាប, ថយថោក : អំពើលាមក, មនុស្សលាមក ។ ខ្មែរប្រើជា ន. សំដៅសេចក្តីថា "ឧច្ចារៈ" ក៏បាន : បន្ទោលាមក, ស្អុយដូចលាមក ។

ប្រឡាក់ ។ ជនណាខ្ចប់ត្រីស្អុយដោយស្បូវភ្លាំង ស្បូវភ្លាំងរបស់ជននោះ ទៅជាមានក្លិនស្អុយផ្សាយទៅ យ៉ាងណាមិញ ការសេពគប់បុគ្គលពាល ក៏យ៉ាងនោះដែរ ។ ជនណាខ្ចប់ក្រស្នា[៦៤] ដោយស្លឹកឈើ ស្លឹកឈើរបស់ជននោះ ទៅជាមានក្លិនក្រអូបផ្សាយទៅ យ៉ាងណាមិញ ការសេពបុគ្គលជាអ្នកប្រាជ្ញ ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បណ្ឌិតកាលដឹងច្បាស់នូវភាពនៃខ្លួនដែលប្រែប្រួលបាន ដូចជាកញ្ចប់នៃស្លឹកឈើ មិនត្រូវសេពគប់អសប្បុរស ត្រូវសេពតែសប្បុរស ព្រោះថាពួកអសប្បុរសតែងនាំទៅកាន់នរក

ពួកសប្បុរសតែងឲ្យដល់សុគតិ[៦៥]" ។

## ព្រះរាជធីតាបង្ហាញអតីតជាតិ

ព្រះរាជធីតា បានសម្តែងនូវធម៌ដល់បិតាដោយពាក្យទាំងនេះ យ៉ាងនេះហើយ តទៅនេះ ព្រះនាងបានបង្ហាញអំពីទុក្ខដែលខ្លួននាងផ្ទាល់បានទទួលរងពីអតីតជាតិ ដូច្នេះ ៖

---

[៦៤] (ន.) ឈ្មោះរុក្ខជាតិមួយយ៉ាងពួកក្លាំពាក់, ចន្ទន៍ខ្លឹមមានក្លិនក្រអូប គេច្រើននិយមប្រើធ្វើជាថ្នាំកែរោគ ។

[៦៥] ដំណើរល្អ, ការទៅដោយល្អ (ចំពោះការស្លាប់កើត); ការប្រព្រឹត្តត្រូវផ្លូវ, ត្រូវគន្លងធម៌; គន្លងឬលំអានយុត្តិធម៌ ។ (បា.) ឋានសួគ៌ : ស្លាប់ទៅកើតក្នុងសុគតិ ។

"ខ្ញុំម្ចាស់បានរលឹកឃើញនូវភាពនៃខ្លួនដែលអន្ទោលទៅមកអស់ ៧ ជាតិមកហើយ នឹង ៧ ជាតិទៀត ដែលខ្ញុំម្ចាស់នឹងច្យុតចាក អត្តភាពនេះ ទៅក្នុងអនាគត ។ បពិត្រព្រះអង្គជាធំជាងជន ក្នុងកាលមុន ក្នុងជាតិជាគម្រប់ ៧ នោះ ខ្ញុំម្ចាស់បានកើតជាកូនជាងមាស ក្នុងរាជគហបូរី ក្នុងដែនមគធៈ ។ បាបដ៏ច្រើនខ្ញុំម្ចាស់បានធ្វើហើយ ព្រោះអាស្រ័យសម្លាញ់ដ៏លាមក ខ្ញុំម្ចាស់ទាំងពីរនាក់កាលបៀតបៀនប្រពន្ធនៃបុគ្គលដទៃ ប្រព្រឹត្តខ្លួនដូចមិនស្លាប់ ។ អំពើនោះ កប់នៅដូចភ្លើងដែលកប់ក្នុងផេះ បពិត្រមហារាជតទៅ ខ្ញុំម្ចាស់បានកើតក្នុងវិសភូមិ ក្រុងកោសម្ពី ជាកូនប្រុសតែមួយ មានគេធ្វើសក្ការៈបូជាជានិច្ចក្នុងត្រកូលសេដ្ឋី ជាត្រកូលស្តុកស្តម្ភ សម្បូរ មានទ្រព្យច្រើន ដោយកម្មដទៃ ។ ក្នុងកាលនោះខ្ញុំម្ចាស់បានសេពគប់មិត្រសម្លាញ់ អ្នកត្រេកអរក្នុងកុសល ជាបណ្ឌិតអ្នកបរិបូណ៌ដោយការចេះដឹង មិត្រនោះបានតម្កល់ខ្ញុំម្ចាស់ក្នុងអំពើជាប្រយោជន៍ ។ ខ្ញុំម្ចាស់បានរក្សាឧបោសថ អស់រាត្រីទី ១៤ និងទី ១៥ ដ៏ច្រើន កម្មនោះនៅកប់ដូចកំណប់ក្នុងទឹក ។ ក៏បណ្តាបាបកម្មទាំងឡាយ បរទារកម្ម[៦៦]ណាដែលខ្ញុំម្ចាស់ បានធ្វើ

[៦៦] អំពើដែលបុរសប្រព្រឹត្តខុសចំពោះភរិយារបស់អ្នកដទៃ គឺអំពើលួចប្រពន្ធគេ : បរ

ហើយក្នុងដែនមគធៈ ផលនៃបរទារកម្មនោះ ផ្តល់ក្នុងកាលជាខាងក្រោយ ដូចបុគ្គលអ្នកបរិភោគភោជន ដែលលាយដោយថ្នាំពិសដ៏កាចដូច្នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកត្រកូលសេដ្ឋីនោះមក ឆេះក្នុងរោរុពនរក[៦៧] អស់កាលដ៏យូរដោយកម្មរបស់ខ្លួន ខ្ញុំម្ចាស់កាលរលឹកឃើញទុក្ខក្នុងនរកនោះ រមែងមិនបានសេចក្តីសុខ ។ ខ្ញុំម្ចាស់ញុំាងសេចក្តីទុក្ខដ៏ច្រើនឲ្យអស់ទៅក្នុងរោរុពនរកនោះអស់ពួកនៃឆ្នាំដ៏ច្រើន បានមកកើតជាពពែគេក្រៀវអណ្ឌៈ[៦៨] ក្នុងក្រុងភិន្នាគតៈ ។ ប៉ុន្តែពពែឈ្មោលនោះ បរិបូណ៌ដោយកម្លាំង ។ ជនទាំងឡាយជិះលើខ្នងហើយ ដេញវាឲ្យដើរទៅបាន សូម្បីទឹមយានក៏បាន" ។

កាលនឹងបញ្ជាក់សេចក្តីនោះ ព្រះនាងរុចាពោលថា ៖

---

ទារកម្ម ជាអំពើលាមកអាក្រក់របស់បុរសពាយផាយ ឈ្វក់ចិត្តងប់ស៊ប់ក្នុងអបាយមុខឈ្មោះឥត្ថីធុត្តៈ ឬ ឥត្ថីធូត, ស្ត្រីទ្យូត ។ បរទារកកម្ម (--កៈក័ម)

[៦៧] ឈ្មោះឋាននរកមួយមានសូរសម្រែកកងរំពង ។ គុ. (ព. ប្រ.) ដែលអនាថាមានទុក្ខវេទនាខ្លាំង ស្រែកថ្ងូរឮរំពងឥតស្រាកឬដែលគគ្រក់កខ្វក់សព្វអន្លើ : មនុស្សរោរព, ផ្ទះរោរព (ម. ព. មហារោរព ក្នុងពាក្យ មហា ផង) ។

[៦៨] អវយវៈមួយប៉ែកនៅត្រង់ខាងក្រោមអង្គជាតបុរស (ព. ខ្ល.; ព. សា. ពងស្វាស ឬពងល្វា) : ហើមអណ្ឌៈ ។ អណ្ឌៈធំ អណ្ឌៈកោប (ពងកោប) ។

"ខ្ញុំម្ចាស់បាននាំពួកកូនអាមាត្យដោយខ្នង[៦៩]ផង ដោយរថផង ការឆេះក្នុងរោរុពនរកជាដើមនោះ ជាផលកម្មគឺការប្រព្រឹត្តខុសក្នុងប្រពន្ធបុគ្គលដទៃ នៃខ្ញុំម្ចាស់នោះ" ។

លុះច្យុតចាកអត្តភាពជាពពែនោះហើយ ពពែនោះចាប់បដិសន្ធិក្នុងកំណើតជាស្វា ។ គ្រានោះ ពួកស្វាបាននាំកូនស្វានោះទៅបង្ហាញដល់ស្វាជាមេហ្វូង ។ មេហ្វូងថា "ចូរនាំកូនមកឲ្យអញ" ។ ពួកគេនាំយកមកឲ្យស្វាមេហ្វូងនោះ ។ ស្វាជាមេហ្វូងចាប់យ៉ាងមាំ កូនស្វាស្រែកយំ ស្វាជាមេហ្វូងនោះក៏ខាំបណ្ដាច់ពងស្វាសកូនស្វានោះ ដោយចង្កូម ។

កាលនឹងបញ្ជាក់សេចក្ដីនោះ ព្រះនាងរុចាពោលដូច្នេះ

"បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ ក៏កើតជាស្វាក្នុងព្រៃធំ ត្រូវស្វាជាម្ចាស់ហ្វូង ជាសត្វឃ្នើសឃ្នង[៧០] ខាំកាត់ផ្ដាច់ពូជចេញ នេះជាផលកម្ម គឺការប្រព្រឹត្តកាមេសុមិច្ឆាចារក្នុងប្រពន្ធបុគ្គលដទៃ នៃខ្ញុំម្ចាស់នោះ" ។

---

[៦៩] នាំទៅដោយខ្នងមានន័យថា អៀវ ក ឬបង្អោប ក ឬជិះលើខ្នង ។

[៧០] (គុ.) ប្រឡើសបើស, ឈ្នះឈ្នាន, ព្រហើន, ឈ្វានពាន, ទ្រើសឃ្នង : មនុស្សឃ្នើសឃ្នង, សំដីឃ្នើសឃ្នង ។

បន្ទាប់មក ព្រះនាងរុចាបង្ហាញនូវជាតិផ្សេង ៗ ទៀត ៖

"បពិត្រព្រះបាទវិទេហៈខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ បានកើតជាគោក្នុងដែនទសន្នៈ ជាគោដ៏ចម្រើន មានសន្ទុះលឿន ត្រូវគេក្រៀវ ខ្ញុំម្ចាស់បានអូសរទេះ អស់កាលដ៏យូរ នេះជាផលកម្មគឺការគប់រកប្រពន្ធអ្នកដទៃ នៃខ្ញុំម្ចាស់នោះ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ បានមកកើតក្នុងត្រកូលក្នុងដែនវជ្ជី ក្នុងអត្តភាពជាមនុស្សដែលគេបានដោយក្រតែមិនមែនស្រីមិនមែនប្រុស ខ្ទើយ នេះជាផលកម្មគឺការគប់រកប្រពន្ធបុគ្គលដទៃនៃខ្ញុំម្ចាស់នោះ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ច្យុតចាកអត្តភាពនោះហើយ បានកើតជាស្រីអប្សរ មានវណ្ណៈគួរប្រាថ្នាក្នុងនន្ទវ័នឧទ្យានក្នុងឋានតាវត្តិង្ស ។ មានសំពត់និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលជាវិការៈនៃកែវមណី ជាស្រីឈ្លាសក្នុងការរាំនិងច្រៀង ជាស្រីបម្រើទេវរាជឈ្មោះ សក្កៈ ។ បពិត្រព្រះបាទវិទេហៈ ខ្ញុំម្ចាស់ឋិតនៅក្នុងឋានតាវត្តិង្សនោះរលឹកឃើញជាតិ ៧ ដែលខ្ញុំម្ចាស់នឹងទៅក្នុងអនាគត ។ កុសលណាដែលខ្ញុំម្ចាស់បានធ្វើហើយ ក្នុងក្រុងកោសម្ពី កុសលនោះតាមមកឲ្យផល ។ ខ្ញុំម្ចាស់ច្យុតចាកអត្តភាព ជាទេពធីតានុ៎ះ នឹងអន្ទោលទៅហើយ ក្នុងទេវលោកនិងមនុស្សលោក ។ បពិត្រមហា

រាជ ខ្ញុំម្ចាស់ដែលគេធ្វើសក្ការបូជាជានិច្ច អស់ជាតិទាំងឡាយ ៧ តែខ្ញុំម្ចាស់នឹងមិនរួចហើយ ចាកភាពជាស្រី អស់គតិ[៧១]៦ នេះ ។ បពិត្រព្រះសម្មតិទេព ក្នុងគតិជាគម្រប់ ៧ ខ្ញុំម្ចាស់នឹងកើតជាទេវតាប្រុស ជាទេវបុត្រមានឫទ្ធិច្រើនដ៏ឧត្តមក្នុងពួកទេវតា ។ ក៏ក្នុងថ្ងៃនេះ នាងទេពកញ្ញាទាំងឡាយ កំពុងតែក្រងផ្កាជាផ្កាំងក្នុងនន្ទវ័ន ទេវបុត្រឈ្មោះជវៈ ជាស្វាមីខ្ញុំម្ចាស់នោះ កំពុងទទួលកម្រងផ្កាដើម្បីខ្ញុំម្ចាស់ ។ ១៦ ឆ្នាំ ក្នុងជាតិរបស់ខ្ញុំម្ចាស់នេះ ហាក់ដូចជាកាលទិព្វនោះ មួយរំពេច មួយយប់មួយថ្ងៃទិព្វនោះ ជា ១០០ ឆ្នាំរបស់មនុស្ស ។ កម្មទាំងឡាយរមែងអន្ទោលតាមគ្រប់ជាតិជាអសង្ខេយ្យដូច្នេះឯង ដ្បិតថា កម្មល្អក្តី លាមកក្តី មិនបាត់បង់ទេ" ។

គ្រានោះ ព្រះនាងរុចាបានសម្ដែងនូវធម៌បន្ថែមដល់ព្រះរាជាថា ៖

> យោ ឥច្ឆេ បុរិសោ ហោតុំ ជាតិំ ជាតិំ បុនប្បុនំ
> បរទារំ វិវជ្ជេយ្យ ធោតបាទោវ កទ្ទមំ។

---

[៧១] ការទៅ, ការដើរទៅ, ដំណើរ; ផ្លូវគន្លង; ទីកើតផ្សេងៗ; និស្ស័យ; អធ្យាស្រ័យ; ប្រាជ្ញាញាណ; ទីនៅ; បរិសុទ្ធ ។

*"បុរសណាប្រាថ្នាឲ្យបានជាកេទបុរសរាល់ ៗ ជាតិ ត្រូវវៀរប្រពន្ធបុគ្គលដទៃ ដូចជាបុគ្គលអ្នកមានជើងលាងហើយ វៀរបង់នូវភក់ដូច្នោះ" ។*

យោ ឥច្ឆេ បុរិសោ ហោតុំ ជាតិំ ជាតិំ បុនប្បុនំ
សាមិកំ អបចាយេយ្យ ឥន្ទំវ បរិចារិកា។

*"ស្ត្រីណាប្រាថ្នាឲ្យបានជាបុរសរាល់ ៗ ជាតិ ត្រូវគោរពប្តីដូចជាពួកស្រីអប្សរ ជាអ្នកបម្រើគោរពព្រះឥន្ទ្រដូច្នោះ" ។*

យោ ឥច្ឆេ ទិព្យភោគញ្ច ទិព្វមាយុំ យសំ សុខំ
បាបានិ បរិវជ្ជេត្វា តិវិធំ ធម្មមាចរេ។

*"បុគ្គលណាចង់បានភោគៈជាទិព្វ[៧២] អាយុ យស និងសុខជាទិព្វ ត្រូវវៀរបង់អំពើបាបទាំងឡាយ ប្រព្រឹត្តសុចរិត[៧៣]ធម៌ ៣ យ៉ាង" ។*

---

*[៧២] ទ្រព្យរបស់ដែលកើតឡើងដោយសារបុណ្យ សម្រេចពីបុណ្យ កើតឯងសមតាមប្រាថ្នា ។*

*[៧៣] ការប្រព្រឹត្តល្អ: កាន់សុចរិត, មានសុចរិត (ហៅ សុចរិតធម៌ ក៏បាន), មាន ៣ យ៉ាង គឺ ការប្រព្រឹត្តល្អដោយកាយ ហៅ កាយសុចរិត;... ដោយវាចា ហៅ វចីសុចរិត; ... ដោយចិត្តសុទ្ធ ហៅ មនោសុចរិត ។ ព. ផ្ទ. ទុច្ចរិត ។*

កាយេន វាចា មនសា    អប្បមត្តោ វិចក្ខណោ
អត្តនោ ហោតិ អត្ថាយ    ឥត្ថី វា យទិ វា បុមា ។

*ស្ត្រីក្តី បុរសក្តី ជាអ្នកមិនធ្វេសប្រហែសដោយកាយវាចាចិត្ត មានប្រាជ្ញាជាគ្រឿងពិចារណា ឈ្មោះថាកើតមកដើម្បីប្រយោជន៍របស់ខ្លួន ។*

យេ កេចិមេ មានុជា ជីវលោកេ
យសស្សិនោ សព្វសមត្តភោគា
អសំសយំ តេហិ បុរេ សុចិណ្ណំ
កម្មស្សកាសេ បុថុ សព្វសត្តា ។

*"ពួកមនុស្សណានីមួយ ក្នុងជីវលោក[៧៤] ជាអ្នកមានយស មានភោគៈបរិបូណ៌ទាំងអស់ ពួកមនុស្សទាំងនោះ បានសន្សំកម្មល្អហើយ ក្នុងកាលមុន ដោយឥតសង្ស័យ សត្វទាំងអស់ជាច្រើន សុទ្ធតែមានកម្មជារបស់ខ្លួន" ។*

ឥង្ឃានុចិន្តេសិ សយម្បិ ទេវ

---

*[៧៤] លោកជាទីរស់នៅរបស់ពពួកសត្វ ។ ពពួកសត្វដែលអាស្រ័យលើពីភពលោក ហើយចិញ្ចឹមជីវិត ។*

កុតោនិទានា តេ ឥមា ជនិន្ទ
យា តេ ឥមា អច្ឆរាសន្និកាសា
អលង្កតា កញ្ចនជាលឆន្នា ។

"បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ត្រិះរិះរឿយ ៗ ដោយព្រះអង្គឯងចុះ បពិត្រព្រះអង្គជាធំជាងជន ស្ត្រីទាំងឡាយណារបស់ព្រះអង្គ ប្រាកដស្មើដោយស្រីអប្សរ[៧៥] មានខ្លួនប្រដាប់ហើយបិទបាំងដោយបណ្ដាញមាស តើស្ត្រីទាំងនេះ របស់ព្រះអង្គមានអ្វីជាហេតុ" ។

ព្រះរាជកញ្ញាព្រះនាមរុចា ថ្វាយយោបល់ព្រះបិតាយ៉ាងនេះញុំាងព្រះបាទអង្គតិ ជាព្រះបិតាឲ្យត្រេកអរយ៉ាងនេះឯង នាងជាអ្នកមានវត្តល្អបានប្រាប់ផ្លូវសុគតិដល់ព្រះបិតា ដូចបុគ្គលប្រាប់ផ្លូវដល់មនុស្សវង្វេង

[៧៥] ស្ត្រីមានសម្បុរថ្លាស្រស់, ផូរផង់ឬស្ត្រីមានមុខថ្លាស្រស់បំព្រង") ស្ត្រីសួគ៌ : ស្រីអប្សរ, ស្រីទេពអប្សរ, នាងអប្សរ ។ តាមសេចក្ដីតំណាលក្នុងគម្ពីរព្រាហ្មណ៍ថា ស្ត្រីសួគ៌ពួកមួយដែលផុសឡើងអំពីទឹក ក្នុងកាលដែលកូរទឹកអម្ឫត (ប៉ុន្តែតាមការណ៍ពិត មិនមែនដូច្នោះទេ, ដែលហៅថា អប្សរ ឬ អប្សរា នោះមានសេចក្ដីថា "ស្រីសួគ៌មានសម្បុរភ្លឺថ្លាផូរផង់ឬស្រីសួគ៌ឆើតឆោម") ។ ខ្មែរប្រើក្លាយជា អក្សរ ក៏មាន : ស្រីអក្សរ, ស្រីទេពអក្សរបវរកញ្ញា (គួរលើកលែងឈប់ប្រើ គួរប្រើ អប្សរ ឬ អប្សរា, អច្ឆរា វិញ ។

នាងបានសម្ដែងសុចរិតធម៌ ។ ព្រះនាងរុចា បានសម្ដែងនូវធម៌ដល់ព្រះបិតា តាំងពីព្រឹកទល់ល្ងាចយ៉ាងនេះ រួចបន្តប្រាប់ថា ៖

"មា, ទេវ, ឧគ្គស្ស មិច្ឆាទិដ្ឋិកស្ស វចនំ គណ្ហិ, 'អត្ថិ អយំ លោកោ, អត្ថិ បរលោកោ, អត្ថិ សុកដទុក្កដកម្មានំ ផលៈន្ដិ វទន្តស្ស មាទិសស្ស កល្យាណមិត្តស្ស វចនំ គណ្ហ, មា អតិត្ថេន បក្ខន្ទី"តិ អាហ ។

"បពិត្រព្រះសម្មតិទេព កុំជឿនូវពាក្យរបស់អ្នកមិច្ឆាទិដ្ឋិ[៧៦] ដែលអាក្រាត[៧៧] នោះឡើយ, លោកនេះមាន បរលោកមាន ផលនៃអំពើល្អ អំពើអាក្រក់ មាន, ការពោលដូច្នេះ ជាពាក្យរបស់

---

[៧៦] សេចក្ដីយល់ឃើញខុស គឺដំណើរយល់ខុសអំពីសេចក្ដីពិត ដូចយ៉ាងយល់ឃើញថា មាតាបិតាគ្មានគុណ, សត្វទាំងអស់ស្លាប់ហើយលែងកើតទៀតជាដើម ។ ព. ផ្ទ. សម្មាទិដ្ឋិ ។

[៧៧] ដែលលែងខ្លួនផ្ទាំងទទេឥតស្លៀកដណ្ដប់សោះឬដែលគ្រាន់តែដណ្ដប់ ប៉ុន្តែមិនស្លៀកបិទបាំងកេរ្តិ៍ខ្មាស, ដែលស្រាតផ្ទាំង : អាក្រាតផ្ទាំង ។ (ព. ខ្ព.; ព. សា. ស្រាត) ។ ប្រើជា កិ. ក៏បាន "ស្រាត" : អាក្រាតខ្លួនទទេ ។ សមណៈ ឬ ស្រមណ៍អាក្រាត អចេលក៍ ។

កល្យាណមិត្រ[៧៨] តួយ៉ាងដូចខ្ញុំម្ចាស់នេះឯង សូមទ្រង់ជឿចុះ, សូមព្រះអង្គកុំស្ទុះទៅតាមមាគ៌ាខុស" ។

[៧៨] មិត្តល្អ, មិត្តត្រឹមត្រូវដែលបុគ្គលគួរសេពគប់ គួររាប់រកយកជាគ្នា ។ ព. ផ្ទ. បាបមិត្ត ។

# ជំពូកទី ៣

## ព្រះរាជារកផ្លូវសេចក្ដីបរិសុទ្ធឃើញ

### រាជធីតារុចាតាំងសច្ចាធិដ្ឋាន

បើទុកជាយ៉ាងនេះក៏ដោយ ព្រះនាងមិនអាចពន្យល់ព្រះរាជបិតាឲ្យរួចចាកមិច្ឆាទស្សនៈបានទេ ។ ពិតមែនហើយ ព្រះរាជាអង្គតិនោះទ្រង់ព្រះសណ្ដាប់នូវវាចាដ៏ពីរោះរបស់ព្រះនាងរុចា ហើយទ្រង់បានត្រឹមតែត្រេកអរប៉ុណ្ណោះ ។ វាជាការណ៍ពិតណាស់ ម្ដាយឪពុកតែងតែស្រឡាញ់នូវសម្ដីរបស់កូនជាទីស្រឡាញ់ទាំងឡាយ ប៉ុន្តែព្រះរាជាអង្គនេះ មិនលះបោលនូវទស្សនៈខុសនោះទេ ។ សូម្បីតែក្នុងនគរ ក៏កើតមានកោលាហល[៧៩]មួយ គឺសេចក្ដីភ្ញាក់ផ្អើលរំជើបរំជួលដែរថា ៖

"បានឮថា ព្រះនាងរុចាសម្ដែងធម៌ដល់ព្រះបិតា ប្រាប់ទ្រង់ឲ្យលះបោលទស្សនៈខុស" ។

មហាជនមានសេចក្ដីត្រេកអរគ្រប់គ្នាដោយនឹកថា ៖

---

[៧៩] សេចក្ដីភ្ញាក់ផ្អើល, ជ្រួលជ្រើម ភាពវឹកវរ : កើតកោលាហល ។

"បណ្ឌិតា រាជធីតា អជ្ជ បិតរំ មិច្ឆាទស្សនា មោចេត្វា ឆករវាសីនំ សោត្ថិភាវំ ករិស្សតិ" ។

*"បណ្ឌិតរាជធីតា ថ្ងៃនេះពន្យល់ព្រះបិតាឲ្យរួចចាកមិច្ឆាទស្សនៈ មុខតែធ្វើនូវសុវត្ថិភាព ជូនដល់អ្នកនគរទាំងឡាយ" ។*

*កាលព្រះនាងរុចាមិនអាចពន្យល់ព្រះបិតាឲ្យយល់បាន ព្រះនាងនៅតែពុំលះបង់នូវព្យាយាម គិតថា ៖*

"យេន កេនចិ ឧបាយេន បិតុ សោត្ថិភាវំ ករិស្សាមិ" ។

*"អញនឹងធ្វើនូវសុវត្ថិភាព[៨០]ដល់បិតា ដោយឧបាយណាមួយឲ្យទាល់តែបាន" ។*

*រួចដាក់អញ្ជលីលើសិរសានមស្ការនូវទិសទាំង ១០ ទាំងអធិដ្ឋានបណ្ដើរថា ៖*

"ឥមស្មិំ លោកេ លោកសន្ធារកា ធម្មិកសមណព្រាហ្មណា នាម លោកបាលទេវតា នាម មហាព្រហ្មានោ នាម អត្ថិ,

---

*[៨០] ការមានសួស្ដី, ការប្រកបដោយសេចក្ដីសុខ : បានត្រឡប់មកដល់ស្រុកវិញ ដោយសុវត្ថិភាព ។ល។*

តេ ឥធាគន្ត្វា អត្តនោ ពលេន មម បិតរំ មិច្ឆាទស្សនំ វិស្សជ្ជាបេន្តុ, ឯតស្ស គុណោ អសតិបិ មម គុណេន មម សីលេន មម សច្ចេន ឥធាគន្ត្វា ឥមំ មិច្ឆាទស្សនំ វិស្សជ្ជាបេត្វា សកលលោកស្ស សោត្ថឹ ករោន្តុ" ។

*"ក្នុងលោកនេះ ឈ្មោះថាសមណព្រាហ្មណ៍អ្នកប្រកបដោយធម៌ លោកបាលទេវតា មហាព្រហ្ម មានពិតប្រាកដ សូមអញ្ជើញពួកលោកមកទីនេះ ជួយប្រាប់ឲ្យបិតាខ្ញុំលះចោលនូវមិច្ឆាទស្សនៈ ដោយកម្លាំងរបស់ខ្លួន ប្ញើដ្បិតតែគុណនៃបិតានោះមិនមានក៏ដោយ តែសូមពួកលោកមកទីនេះ ដោយគុណរបស់ខ្ញុំ ដោយសីលរបស់ខ្ញុំ ដោយសច្ចៈរបស់ខ្ញុំ ជួយពន្យល់បិតាខ្ញុំនេះឲ្យលះចោលនូវមិច្ឆាទស្សនៈ ធ្វើនូវសុវត្ថិភាពដល់សកលលោកផង" ។*

## មហាព្រហ្មនារទ

*គ្រានោះ ពោធិសត្វ កើតជាមហាព្រហ្មឈ្មោះថា **នារទៈ** ។ ជាធម្មតាពោធិសត្វទាំងឡាយ តែងតែប្រមើលមើលនូវលោក ជាញឹកញាប់ដើម្បីឃើញនូវសត្វទាំងឡាយ អ្នកដើរផ្លូវត្រូវនិងដើរផ្លូវខុស*

ដោយមេត្តាការនោ[៩១]របស់ព្រះអង្គ និងដោយសេចក្តីអាណិតអាសូរដ៏សែនធំធេង ។ កាលនារទមហាព្រហ្ម ប្រមើលមើលក្នុងថ្ងៃនោះ បានទតឃើញនូវព្រះរាជធីតានោះ កំពុងតែនមស្ការទេវតាទាំងឡាយអ្នកទ្រទ្រង់លោក ស្នើសូមឲ្យជួយដោះបិតាចាកមិច្ឆាទិដ្ឋិ លោកគិតថា ៖

"លើកលែងតែអញចេញ គ្មានបុគ្គលណាមានសមត្ថភាពពន្យល់ស្តេចនុ៎ះឲ្យលះនូវមិច្ឆាទស្សនៈបានទេ ក្នុងថ្ងៃនេះ គួរណាស់តែអញធ្វើសេចក្តីសង្គ្រោះដល់ព្រះរាជធីតា និងធ្វើនូវសុវត្ថិភាពដល់ព្រះរាជាព្រមទាំងបរិជនរបស់ព្រះអង្គផង ហើយសឹមត្រឡប់មកវិញ តើអញនឹងទៅដោយភេទដូចម្តេចហ្ន៎ ?"

លោកធ្វើសេចក្តីសន្និដ្ឋានថា៖

"បព្វជិតទាំងឡាយជាទីស្រឡាញ់របស់មនុស្សទាំងឡាយផង ជាទីគោរពផង ជាទីទុកចិត្តផង ដូច្នោះអញនឹងទៅដោយភេទបព្វជិតចុះ" ។

[៩១] ការចម្រើនមេត្តា, ដូចយ៉ាងរំពឹងថា សូមឲ្យសត្វទាំងឡាយបានសេចក្តីសុខពល់គ្នាធ្វើឲ្យកើតមានច្រើនក្នុងចិត្ត! ... ។

នារទមហាព្រហ្ម បាននិម្មិតខ្លួនជាមនុស្ស មានពណ៌ដូចមាស ជាទីជ្រះថ្លា ចងជដាមណ្ឌល[៨២] គួរឲ្យគាប់ចិត្ត សៀតស្មៀតសក់មាសក្នុងចន្លោះជដា ស្លៀកនិងដណ្ដប់សំពត់សំបកឈើពណ៌ក្រហមពីលើបជាក្រហមខាងក្នុងពាក់ធៀងស្នាម្ខាងនូវស្បែកខ្លាជាវិការៈនៃប្រាក់ វិចិត្រដោយសុវណ្ណតារា រួចកាន់យកភាជន៍បាយជាវិការៈនៃមាស ដែលដាក់ទុកក្នុងស្នោកកែវមុក្តា ហើយបានរែកនូវសម្រែកដែលឱនចុះក្នុងទីទាំង ៣ យកកែវប្រពាលអំពីថង់កែវមុក្តាហ្នឹងដែរ ហោះមកតាមអាកាសដោយភេទជាឥសីរុងរឿងមើលទៅដូចជាព្រះចន្ទនៅឰដ៏ផ្ទៃនភាល័យ[៨៣] រួចចូលទៅកាន់ព្រះរាជមន្ទីរ[៨៤] នៃប្រាសាទចន្ទ ដែលតុបតែងយ៉ាងស្អាតឈរឰដ៏អាកាស ចំពោះមុខព្រះភក្ត្រនៃព្រះបាទវិទេហៈ ។ នាងរុចាបានឃើញនារទព្រហ្មនោះដែលមកដល់ហើយ ក៏ថ្វាយបង្គំនារទព្រហ្មដែលតំណែងខ្លួនជាឥសី ។

---

[៨២] មណ្ឌលផ្នួងសក់របស់តាបស។

[៨៣] លំនៅពពក គឺមេឃ, អាកាស : អណ្ដែតត្រសែតកណ្ដាលនភាល័យ ។

[៨៤] ផ្ទះដែលព្រះរាជាទ្រង់គង់នៅ (ព្រះរាជមន្ទីរ) ។

## សំណួរចម្លើយនៃនារទៈនិងព្រះរាជា

ចំណែកព្រះរាជា គ្រាន់តែឃើញឥសីភ្លាម ទ្រង់ត្រូវតេជះនៃព្រហ្ម គំរាមធ្វើឲ្យទ្រង់តក់ស្លុត កាលទ្រង់មិនអាចឋិតនៅលើអាសនៈ[៩៥] នៃទ្រង់បាន ទ្រង់ក៏យាង់ចុះចាកអាសនៈ ឈរលើផែនដី សួរនូវទីលំនៅ ដែលអញ្ជើញមកនិងនាមគោត្រថា ៖

> លោកមានវណ្ណៈដូចទេវតា ញុំាងទិសទាំងអស់ឲ្យភ្លឺដូចព្រះចន្ទ តើទើបនឹងមកអំពីទីណា ? យើងសួរហើយ លោកចូរប្រាប់នាម និងគោត្រ មនុស្សទាំងឡាយក្នុងមនុស្សលោក តើគេស្គាល់លោក បានដូចម្តេច ?"

គ្រានោះ ឥសីនោះគិតថា "ស្តេចអង្គនេះសម្គាល់ថា បរលោកមិនមាន, ដូច្នេះអញនឹងប្រាប់បរលោកដល់ព្រះអង្គជាមុនចុះ" ហើយឥសីបាន ពោលដូច្នេះ ៖

"អហញ្ហិ ទេវតោ ឥទានិ ឯមិ ឱភាសយំ សព្វទិសា ចន្ទិមាវ;
អក្ខាមិ តេ បុច្ឆិតោ នាមគោត្តំ, ជានន្តិ មំ នារទោ កស្សបោ ច"។

---

[៩៥] ទីអង្គុយ, កន្លែងអង្គុយ, កម្រាលឬប្រដាប់សម្រាប់អង្គុយ : អង្គុយលើអាសនៈស្មើគ្នា ។ ព. កា. ច្រើនប្រើ អាសន៍ ជាង : កុំអាលប្រឡាស អង្គុយដើមអាសន៍ រួចបែរជាថយ ចុះមកចុងអាសន៍ ឲ្យខ្មាសស្តាយក្រោយ ប្រយ័ត្នកុំធ្លោយ ឲ្យខ្សោយភាពខ្លួន ។

"អាត្មាភាពទើបនឹងមកអំពីទេវលោក ក្នុងកាលឥឡូវនេះ ញុំាង ទិសទាំងអស់ឲ្យភ្លឺដូចព្រះចន្ទ អាត្មាភាពដែលព្រះអង្គសួរហើយ និងទូលនាមនិងគោត្រថា មនុស្សទាំងឡាយស្គាល់អាត្មាភាពថា នារទៈ ជាកស្សបគោត្រ" ។

គ្រានោះ ព្រះរាជាមានព្រះចិន្តាថា "បញ្ហាបរលោក អញទុកសួរឥសី នេះពេលក្រោយចុះ ឥឡូវអញនឹងសួរហេតុនៃការបានឫទ្ធិជាមុន" ដូច្នេះហើយ ព្រះរាជាទ្រង់ត្រាស់សួរថា ៖

"អច្ឆេររូបំ តវ យាទិសញ្ច, វេហាយសំ គច្ឆសិ តិដ្ឋសី ច;
បុច្ឆាមិ តំ នារទ ឯតមត្ថំ, អថ កេន វណ្ណេន តវាយមិទ្ធិ"។

"សណ្ឋានរបស់លោកប្រាកដយ៉ាងណាផង លោកកំពុងដើរក្តី កំពុងឈរក្តី ឰដ៏អាកាសផង នេះមានសភាពជាអស្ចារ្យ បពិត្រ នារទៈ ខ្ញុំសួរសេចក្តីនេះនឹងលោក តើឫទ្ធិរបស់លោកនេះ មាន ដោយហេតុអ្វី?"

នារទៈឆ្លើយថា ៖

"សច្ចញ្ច ធម្មោ ច ទមោ ច ចាគោ, គុណា មមេតេ បកតា បុរាណា; តេហេវ ធម្មេហិ សុសេវិតេហិ, មនោជលោ យេន កាមំ គតោស្មិ" ។

*"សច្ចៈ ១ ធម៌ ១ ទមៈ ១ ចាគៈ ១ គុណធម៌នេះ អាត្មាភាពបានសាងមកហើយអំពីជាតិមុន អាត្មាភាពមានសន្ទុះចិត្តទៅតាមប្រាថ្នាបាន ព្រោះធម៌ដែលអាត្មាភាពសេពល្អហើយទាំងនោះឯង" ។*

*ព្រះរាជា បើទុកណាជាឥសីប្រាប់យ៉ាងនេះ ក៏ទ្រង់នៅតែមិនជឿនូវបរលោក ព្រោះព្រះអង្គប្រកាន់នូវមិច្ឆាទស្សនៈ ទ្រង់លាន់មាត់ថា "ឱ! ផលនៃបុណ្យ មានដែរហ្ន៎" រួចទ្រង់ត្រាស់បន្តថា ៖*

*"ឥឡូវនេះ លោកប្រាប់ការសម្រេចនៃបុណ្យជារបស់អស្ចារ្យហើយ បពិត្រនារទៈ ប្រសិនបើដូចជាលោកពោលយ៉ាងនេះមែន ខ្ញុំសូមសួរសេចក្ដីនេះនឹងលោកទៀត បើខ្ញុំសួរហើយ សូមលោកឆ្លើយឲ្យប្រពៃចុះ" ។*

*នារទឆ្លើយថា ៖*

បុច្ឆស្សុ មំ រាជ តវេស អត្ថោ យំ សំសយំ កុរុសេ ភូមិបាល

អហំ តំ និស្សំសយតំ ករោមិ នយេហិ ញាយេហិ ច ហេតុភី ច ។

"បពិត្រព្រះរាជាជាភូមិបាល[៨៦] ព្រះអង្គនៅមានសេចក្ដីសង្ស័យយ៉ាងណា ៗ សូមទ្រង់សួរអាត្មាភាពចុះ អាត្មាភាពជាប្រយោជន៍របស់ព្រះអង្គ ហើយអាត្មាភាពនឹងញុំាងព្រះអង្គឲ្យដល់នូវភាពជាអ្នកអស់សេចក្ដីសង្ស័យ ដោយន័យ ដោយញាណ និងដោយហេតុទាំងឡាយ" ។

ព្រះរាជាត្រាស់សួរថា ៖

"បពិត្រនារទៈ ខ្ញុំសូមសួរសេចក្ដីនេះនឹងលោក បពិត្រនារទៈ ខ្ញុំសួរហើយ លោកកុំពោលមុសាវាទឡើយ នរជនបានសួរថា ទេវតា មានឬ? មាតាបិតាមានឬ? បរលោក[៨៧]មានឬ?" ។

---

[៨៦] ឈ្មោះក្រុមក្នុងក្រសួងរាជការ មានមុខងារនាទីខាងកាន់កាប់បញ្ជីដីភូមិ និងដីស្រែចម្ការរបស់ប្រជាពលរដ្ឋ : ការិយាល័យនៃភូមិបាល, ចាត់ភ្នាក់ងារភូមិបាលឲ្យទៅអង្កេតដីចម្ការដែលកើតហេតុ ស្ដេចផែនដី ហៅថាភូមិបាល។

[៨៧] លោកឯមុខ : ទៅកាន់បរលោកហើយ គឺធ្វើមរណកាលទៅកាន់លោកឯខាងមុខហើយ ។ ព. ផ្ទ. ឥធលោក ។

*នារទឆ្លើយថា ៖*

អត្ថិ ទេវា បិតរោ ច អត្ថិ លោកោ បរោ អត្ថិ ជនោ យមាហុ
កាមេសុ គិទ្ធា ច នរា បមូឡ្ហា លោកំ បរំ ន វិទូ មោហយុត្តា។

*"នរជនបានពោលថា ទេវតាមាន មាតាបិតាមាន បរលោកមាន ពួកជនជាអ្នកជាប់ក្នុងកាម ជាអ្នកវង្វេងប្រកបដោយមោហៈ រមែងមិនបានដឹងនូវបរលោកឡើយ" ។*

*លុះឮដូច្នោះ ព្រះរាជាធ្វើការសើចចំអក ហើយទ្រង់ត្រាស់ថា ៖*

*"បពិត្រនារទៈ ប្រសិនបើលោកជឿថា លំនៅនៃជនទាំងឡាយដែលស្លាប់ទៅហើយ មានក្នុងបរលោកមែន សូមលោកឲ្យខ្ញុំខ្ចីប្រាក់ ៥០០ កហាបណៈ ក្នុងលោកនេះសិនចុះ ចាំដល់ទៅបរលោក ខ្ញុំនឹងសងលោកវិញ ១.០០០ កហាបណៈ" ។*

*គ្រានោះ ព្រះមហាសត្តរិះគន់ព្រះរាជាក្នុងកណ្ដាលបរិស័ទថា ៖*

ទទេម្មុ ខោ បញ្ច សតានិ ភោតោ ជញ្ញាមុ ចេ សីលវន្តំ វទញ្ញុំ
លុទ្ធំ តំ ភោន្តំ និរយេ វសន្តំ កោ ចោទយេ បរលោកេ
សហស្សំ។

ឥធេវ យោ ហោតិ អធម្មសីលោ, បាបាចារោ អលសោ
លុទ្ទកម្មោ ន បណ្ឌិតា តស្មឹ ឥណំ ទទន្តិ ន ហិ អាគមោ
ហោតិ តថាវិធម្ហា។
ទក្ខញ្ច បោសំ មនុជា វិទិត្វា, ឧដ្ឋានកំ សីលវន្តំ វទញ្ញុំ;
សយមេវ ភោគេហិ និមន្តយន្តិ, កម្មំ ករិត្វា បុន មាហរេសិ”។

*“ប្រសិនបើយើងដឹងនូវអ្នកដ៏ចម្រើនថាមានសីល ជាអ្នកដឹងនូវពាក្យស្នូម យើងនឹងឲ្យ ៥០០ កហាបណៈ ដល់អ្នកដោយឥតមានស្ទាក់ស្ទើរឡើយ ប៉ុន្តែបើអ្នកជាមនុស្សអាក្រក់នោះ មានដំណើរទៅក្នុងនរក តើបុគ្គលណានឹងទៅតាមទារកហាបណៈ ១.០០០ ក្នុងបរលោកបាន ។ សូម្បីក្នុងលោកនេះ បុគ្គលណាមិនមានធម៌ជាប្រក្រតី មានមារយាទដ៏លាមក ជាអ្នកខ្ជិលច្រអូស មានការងារអាក្រក់ ពួកបណ្ឌិតក៏មិនឲ្យបុគ្គលនោះបុលទ្រព្យទេ ព្រោះថា ការបានទ្រព្យអំពីបុគ្គលមានប្រការដូច្នោះ មិនមានឡើយ ។ ពួកមនុស្សដឹងនូវបុរសថា ជាអ្នកប៉ិនប្រសប់ មានព្យាយាម មានសីល ជាអ្នកដឹងពាក្យស្នូម រមែងអញ្ជើញខ្លួនឯងដោយភោគៈទាំងឡាយថា អ្នកធ្វើការងារហើយ គប្បីសងយើងវិញ” ។*

## នារទៈសម្តែងនិរយកថា

ដោយប្រការយ៉ាងនេះ ព្រះរាជាត្រូវឥសីនោះផ្ចាញ់ផ្ចាល់ហើយ ទ្រង់ទាល់តម្រិះតបតលែងកើត ។ មហាជនរីករាយត្រេកអរ ។ កើតមានសភាពអ៊ូអរទូទាំងនគរថា "ទេវតាមានឫទ្ធិច្រើនថ្ងៃនេះ ញ៉ាំងព្រះរាជាឲ្យទ្រង់លះបង់នូវមិច្ឆាទស្សនៈ" ។ គ្រានោះ ក្រុងមិថិលាមានទំហំ ៧ យោជន៍ អ្នកក្រុងនេះទាំងអស់បានស្តាប់ធម្មទេសនារបស់នារទព្រហ្មគ្រប់ ៗ គ្នា ដោយអានុភាពនៃព្រះមហាសត្វ ។ គ្រានោះ មហាសត្វគិតថា "ព្រះរាជានេះ ប្រកាន់ទស្សនៈខុសមាំខ្ជាំងណាស់ អញនឹងលើកយកភ័យក្នុងនរកមកគំរាមស្តេចនោះ ធ្វើឲ្យទ្រង់លះមិច្ឆាទិដ្ឋិ ហើយនិងលើកទេវលោកមកលួងលោមព្រះអង្គជាថ្មី" ។ លុះគិតដូច្នេះហើយ ឥសីពោលថា ៖

"មហារាជ សចេ ទិដ្ឋឹ ន វិស្សជ្ជេស្សសិ ឯវំ អនន្តទុក្ខំ និរយំ គមិស្សសិ" ។

"បពិត្រមហារាជ ប្រសិនបើព្រះអង្គមិនលះបង់នូវទិដ្ឋិនោះទេ កាលបើយ៉ាងនេះ ព្រះអង្គមុខតែទៅកាន់នរកដែលមានទុក្ខឥតទីបំផុត" ។

*រួចព្រះអង្គថ្លែងនិរយកថាដូច្នេះ*

"ឥតោ ចុតោ ឧក្ខសិ តត្ថ រាជ កាកោលសង្ឃេហិ
វិកស្សមានំ តំ ខជ្ជមានំ និរយេ វសន្តំ កាកេហិ គិជ្ឈេហិ ច
សេនកេហិ សញ្ឆិន្នគត្តំ រុហិរំ សវន្តំ កោ ចោទយេ
បរលោកេ សហស្សំ" ។

*"បពិត្រព្រះរាជា បើព្រះអង្គច្យុតចាកអត្តភាពនេះទៅ នឹងទតឃើញខ្លួនព្រះអង្គ ដែលហ្វូងក្អែកកំពុងចឹកជញ្ជែងក្នុងនរកនោះ ព្រះអង្គគង់ក្នុងនរក ដែលហ្វូងក្អែក ត្មាត និងឆ្កែកំពុងខាំស៊ី មានខ្លួនធ្លុះធ្លាយកំពុងហូរឈាម បុគ្គលណានឹងទៅទារកហាបណៈ ១.០០០ ក្នុងបរលោកបាន" ។*

*លុះពណ៌នានូវកាកោលនរកនោះរួចហើយ ឥសីនោះពោលថា ៖*

សចេបិ ឯត្ថ ន និព្វត្តិស្សសិ លោកន្តរនិរយេ និព្វត្តិស្សសិ ។

"ប្រសិនបើព្រះអង្គមិនកើតក្នុងនរកនោះទេ ព្រះអង្គមុខតែកើតក្នុងនរកលោកន្តរ[៨៨]" ។

រួចលោកបន្តពោលនិរយកថានោះដូច្នេះ

អន្ធំតមំ តត្ថ ន ចន្ទសូរិយា និរយោ សទា តុមុលោ ឃោររូបោ
សា នេវ រត្តី ន ទិវា បញ្ញាយតិ តថាវិធេ កោ វិចរេ ធនត្ថិកោ។

"ភាពងងឹតខ្លាំងរមែងមានក្នុងនរកនោះ ព្រះចន្ទនិងព្រះអាទិត្យក៏មិនមាន នរកនោះមានងងឹតដ៏ក្រាស់សព្វកាល ជាកន្លែងឃាត់នូវចក្ខុវិញ្ញាណមិនឲ្យកើតឡើង មានសភាពគួរខ្លាច យប់ក៏ងងឹត ថ្ងៃក៏ងងឹត នរណាជាអ្នកត្រូវការដោយទ្រព្យ គប្បីត្រាច់ទៅក្នុងនរក ក៏ដូច្នោះដែរ" ។

---

[៨៨] រណ្ដៅនៅក្នុងចន្លោះនៃលោក ជាឈ្មោះរណ្ដៅនរក ដែលសត្វជាបុថុជ្ជនប្រភេទខ្លះប្រកាន់ឧច្ឆេទទិដ្ឋិ ជឿស៊ប់ថាគ្មានបុណ្យគ្មានបាបសួគ៌នរកអ្វីទេ សត្វស្លាប់ទៅក៏សូន្យឈឹងឥតមានជាតិកំណើតតទៅទៀតឡើយ, នរកនេះកើតមានព្រោះលទ្ធិនោះឯង ។ល។ (ព. ពុ.) : លទ្ធិពុទ្ធនិយមថា សត្វជាបុថុជ្ជនណាដែលប្រកាន់ជឿថាស្លាប់ទៅសូន្យឥតមានជាតិកំណើតតទៅទៀតទេ, បុថុជ្ជននោះ កាលបើស្លាប់ក៏តែងតែកើតក្នុងលោកន្តរនរក ភ្លើងប្រល័យកប្បក៏ពុំឆេះរំលាយនរកនោះឡើយ ។

លុះពណ៌នានូវនរកលោកនូវនោះយ៉ាងពិស្ដារថ្វាយព្រះរាជាយ៉ាង នេះហើយឥសីពោលថា ៖

"មហារាជ, មិច្ឆាទិដ្ឋឹ អវិស្សជ្ជេន្តោ ន កេវលំ ឯតទេវ, អញ្ញម្បិ ទុក្ខំ អនុភវិស្សសិ" ។

"បពិត្រមហារាជ កាលបើមិនលះចោលនូវមិច្ឆាទិដ្ឋិ ព្រះអង្គមិនមែនត្រឹមតែសោយទុក្ខតែប៉ុណ្ណឹងទេអាចសោយនូវទុក្ខដទៃផ្សេងទៀត" ។

ហើយបន្តថ្លៃងថា ៖

"ឆ្កែពពាលនិងឆ្កែលឿងទាំងពីរពួក មានកាយធាត់ធំ មានកម្លាំងតែងខាំស៊ី នូវសត្វដែលច្យុតអំពីលោកនេះ ធ្លាក់ទៅក្នុងបរលោកដោយធ្មេញជាវិការៈនៃដែក ។ ព្រះអង្គកាលនៅក្នុងនរក ត្រូវពួកឆ្កែដ៏កាចសាហាវ អាក្រក់ ខាំស៊ី មានខ្លួនផុះផ្លាយ កំពុងហូរឈាមនាំមកនូវសេចក្ដីទុក្ខដ៏ខ្លាំងក្លា តើនរណានឹងទារកហាបណៈ ១.០០០ ក្នុងបរលោកបាន ។ ពួកនាយនិរយបាល ឈ្មោះកាលូបកាលៈក្នុងនរកគួរខ្លាចដ៏ពន្លឹក ជាបច្ចាមិត្រ តែងសម្លាប់ឬចាក់នរជន ដែលធ្វើអំពើអាក្រក់ក្នុងកាលមុន ដោយព្រួញនិងលំពែង

ដែលសំលៀងយ៉ាងមុត ។ ព្រះអង្គកាលទៅក្នុងនរកនោះ ត្រូវនាយនិរយបាល ចាក់ត្រង់ភ្លៀក ត្រង់ឆ្អឹងជំនីរ វះពោះ មានខ្លួនផ្ទុះធ្លាយ មានឈាមហូរចេញ តើនរណានឹងទារកហាបណៈ ១.០០០ ក្នុងបរលោកបាន ។ ក្នុងនរកនោះ មានភ្លៀងបង្អុរចុះជាអាវុធផ្សេង ៗ គឺលំពែង ព្រួញ លំពែងស្នែងក្របី និងច្បូក ភ្លៀងអាវុធ មានអណ្ដាតដូចជារងើកភ្លើង រមែងធ្លាក់លើក្បាល រន្ទះថ្មរមែងបង្អុរចុះលើបុគ្គលអ្នកមានអំពើអាក្រក់ ។ ក្នុងនរកនោះមានខ្យល់ដ៏ក្ដៅដែលអត់ធន់បានដោយក្រ ព្រះអង្គដែលមានកម្មអាក្រក់ រមែងមិនបានសេចក្ដីសុខតិចតួចក្នុងនរកនោះឡើយ តើនរណានឹងទារកកហាបណៈ ១.០០០ ក្នុងបរលោកពីព្រះអង្គនោះ ដែលក្ដៅក្រហាយជានិច្ច ស្ទុះទៅមក មិនមានទីពួន ។ ព្រះអង្គស្ទុះទៅស្ទុះមកដែលនាយនិរយបាលទឹមក្នុងរថ ព្រះអង្គជាន់ផែនដីមានអណ្ដាតភ្លើងសន្ធោសន្ធៅ ដែលនាយនិរយបាលកំពុងចាក់ដោយជន្លួញ តើនរណានឹងទារកហាបណៈ ១.០០០ ក្នុងបរលោកបាន ? ព្រះអង្គឡើងកាន់ភ្នំ ដ៏ដេរដាសដោយកាំបិត ជាភ្នំគួរស្ញើប មានអណ្ដាតភ្លើងប្រាលរន្ទាលឆ្អិនឆ្អៅគួរខ្លាច ព្រះអង្គមានខ្លួនផ្ទុះធ្លាយកំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១.០០០ ក្នុងបរលោកបាន ។ ព្រះអង្គឡើងកាន់គំនររងើកភ្លើង

ប្រាកដស្មើដោយភ្នំដ៏ប្រាល ឆ្អៅគួរខ្លាច មានខ្លួនឆេះសព្វ ជាសត្វ កំព្រាទួញយំ តើនរណានឹងទារកហាបណៈ ១.០០០ ក្នុងបរលោក បាន ។ ដើមឈើដ៏ខ្ពស់ស្មើនឹងពពក វិចិត្រដោយបន្លាដ៏មុត ជា វិការៈនៃដែក ជាបន្លាបឺតជញ្ជក់ឈាមរបស់នរជន ។ ពួកស្ត្រីនិង បុរស ដែលក្បត់ប្រព្រឹត្តខុសក្នុងប្រពន្ធនៃបុគ្គលដទៃ ត្រូវពួក នាយនិរយបាលមានដាវក្នុងដៃ ជាអ្នកធ្វើតាមពាក្យរបស់យមរាជ ចាក់ហើយ រមែងឡើងដើមឈើនោះ ។ ព្រះអង្គនឹងឡើងដើមរកា ក្នុងនរក មានកាយរាត់រាយប្រឡាក់ដោយឈាម មានស្បែករបក ក្តៅក្រហាយជានិច្ច មានវេទនាដ៏ខ្លាំង ដកដង្ហើមក្តៅរឿយ ៗ មាន កំហុសព្រោះបុព្វកម្ម មានខ្លួនរបកស្បែកនៅលើចុងបន្លារកា តើ នរណានឹងទៅទារទ្រព្យនោះ ពីព្រះអង្គបាន ។ ដើមឈើខ្ពស់ស្មើ នឹងពពក វិចិត្រដោយស្លឹកជាដាវ ជាវិការៈនៃដែកដ៏មុត ជាស្លឹក បឺតជញ្ជក់ឈាមនៃនរជន ។ ព្រះអង្គនឹងឡើងដើមរកាមានស្លឹក ជាដាវ ត្រូវនាយនិរយបាលកាប់ដោយដាវដ៏មុត មានខ្លួនធ្លុះ ធ្លាយកំពុងហូរឈាម តើនរណានឹងទារកហាបណៈ ១.០០០ ក្នុង បរលោកបាន ។ ព្រះអង្គនឹងដើរចេញអំពីនរក មានដើមរកា មាន ស្លឹកជាដាវនោះ ហើយក៏ធ្លាក់ទៅក្នុងស្ទឹងនរក ឈ្មោះវេត្តរណី តើនរណានឹងទារទ្រព្យនោះពីព្រះអង្គបាន ។ ស្ទឹងនរកឈ្មោះ

*វេត្តរណីដ៏កាចសាហាវមានទឹកផ្សាក្តៅលំបាកខ្លាំងផុតណាស់ ក្នុងនរកនេះដ៏ដេរដាសដោយស្ទឹកឈូកជាវិការៈដែក សត្វនរករមែងមុតដោយស្ទឹកដ៏មុតនោះ ។ ព្រះអង្គមានខ្លួនធុះធ្លាយ ប្រឡាក់ដោយឈាម ដែលខ្សែទឹកហូរក្បួចទៅក្នុងស្ទឹងនរកឈ្មោះវេត្តរណីនោះជាស្ទឹងមិនមានអ្វីតោងទេ តើនរណានឹងហ៊ានទៅទារទ្រព្យនោះពីព្រះអង្គបាន ?"*

## នារទៈព្រហ្មសម្ដែងផ្លូវនៃសេចក្ដីបរិសុទ្ធ

*ព្រះរាជា ទ្រង់ព្រះសណ្ដាប់នូវនិរយកថារបស់ព្រះមហាសត្វត្រឹមតែប៉ុណ្ណេះ ទ្រង់មានហឫទ័យសង្វេគ ក្លាយជាមនុស្សអ្នកស្វែងរកទីពឹងហើយទ្រង់មានព្រះរាជឱង្ការថា ៖*

វេធាមិ រុក្ខោ វិយ ឆិជ្ជមានោ ទិសំ ន ជានាមិ បមូឡ្ហសញ្ញោ;
ភយានុតប្បាមិ មហា ច មេ ភយា សុត្វាន កថា តវ
ភាសិតា ឥសេ។

*"ខ្ញុំញាប់ញ័រ ដូចជាដើមឈើបម្រុងបាក់ ខ្ញុំវង្វេងសញ្ញា មិនដឹងទិស ក្ដៅក្រហាយរឿយ ៗ ព្រោះភ័យនឹងបាបដែលខ្លួនធ្វើហើយ បពិត្រឥសី ភ័យដ៏ធំកើតឡើងដល់ខ្ញុំ ព្រោះបានស្ដាប់គាថាដែលលោកសម្ដែងហើយ ។*

អានិត្តេ ភារិមជ្ឈំវ ធីបំវាយេ មហណ្ណវេ;
អន្ធការេ បជ្ជោតោ ត្វំ នោសិ សរណំ ឥសេ។

បពិត្រឥសី សូមលោកជាទីពឹងរបស់ខ្ញុំ ដូចជាបុគ្គលកាលចុះទៅកាន់ទីពាក់កណ្តាលទឹក ព្រោះកាយ ត្រូវភ្លើងកំពុងឆេះ ឬដូចជាកោះរបស់ពួកជន ដែលធ្លាយសំពៅ ក្នុងអន្ទង់ធំ ក្នុងមហាសមុទ្រ ឬក៏ដូចជាប្រទីបរបស់ពួកជនអ្នកទៅក្នុងទីងងឹត ។

"អត្ថញ្ច ធម្មំ អនុសាស មំ ឥសេ, អតីតមទ្ធា អបរាធិតំ មយា;
អាចិក្ខ មេ នារទ សុទ្ធិមគ្គំ, យថា អហំ នោ និរយំ បតេយ្យំ" ។

បពិត្រឥសី សូមលោកប្រៀនប្រដៅអត្ថនិងធម៌ ដល់ខ្ញុំចុះ កំហុសខ្ញុំបានប្រព្រឹត្តកន្លងហើយអស់កាលយូរ បពិត្រនារទៈ សូមលោកប្រាប់ផ្លូវសេចក្តីបរិសុទ្ធិដល់ខ្ញុំ កុំឲ្យខ្ញុំធ្លាក់ទៅនរកឡើយ" ។

លំដាប់នោះ ព្រះមហាសត្ត ហេតុតែដើម្បីប្រាប់នូវផ្លូវនៃសេចក្តីបរិសុទ្ធ លោកក៏បានបង្ហាញទាក់ទងទៅនឹងឧទាហរណ៍នៃព្រះរាជាអំពីបុរាណ ដែលពួកព្រះអង្គយាងក្នុងផ្លូវត្រូវ តទៅនេះថា ៖

"យថា អហុ ធតរដ្ឋោ

វេស្សាមិត្តោ អដ្ឋកោ យាមតគ្គិ;
ឧសិន្នរោ ចាបិ សិវី ច រាជា បរិចារកា
សមណព្រាហ្មណានំ។

"*ព្រះបាទធតរដ្ឋ ១ វេស្សាមិត្ត ១ អដ្ឋកៈ ១ យមទគ្គិ ១ ឧសិន្នរៈ ១ សិវិ ១ ព្រះរាជាទាំង ៦ អង្គនេះ នឹងពួកព្រះរាជាដទៃ ជាអ្នកបម្រើនូវសមណព្រាហ្មណ៍ ទៅកាន់វិស័យឋានសួគ៌យ៉ាងណា ។*

ឯតេ ចញ្ញេ ច រាជានោ យេ សគ្គវិសយំ គតា
អធម្មំ បរិវជ្ជេត្វា ធម្មំ ចរ មហីបតិ។

*បពិត្រ ព្រះអង្គជាធំលើផែនដី ព្រះអង្គចូរវៀរអធម៌ ហើយប្រព្រឹត្តធម៌យ៉ាងនោះចុះ ។*

"អន្នហត្ថា ច តេ ព្យម្ហេ, ឃោសយន្តុ បុរេ តវ;
កោ ឆាតោ កោ ច តសិតោ, កោ មាលំ កោ វិលេបនំ;
នានារត្តានំ វត្ថានំ, កោ នគ្គោ បរិទហិស្សតិ។

*ម្យ៉ាងទៀត ពួករាជបុរសអ្នកកាន់យកបាយក្នុងប្រាសាទរបស់ព្រះអង្គក្តី ក្នុងបុរីរបស់ព្រះអង្គក្តី ចូរឃោសនាថា នរណាឃ្លាន នរណា*

ស្រេក នរណាចង់បានកម្រងផ្កា នរណាចង់បានគ្រឿងលាប នរណាអាក្រាត ចង់ស្លៀកដណ្តប់សំពត់ជ្រលក់ពណ៌ផ្សេង ៗ ។

កោ បន្ថេ ជត្ថមានេតិ ចាទុកា ច មុទ្ទ សុភា
ឥតិ សាយញ្ច ចាតោ ច ឃោសយន្តុ បុរេ តវ ។

"នរណាចង់បាំងឆត្រដើរក្នុងផ្លូវ នរណាចង់បានស្បែកជើងដ៏ទន់ល្អ ពួករាជបុរស ចូរឃោសនាក្នុងបុរីរបស់ព្រះអង្គរាល់ព្រឹករាល់ល្ងាចដូច្នោះឯង" ។

ជិណ្ណំ ទោសំ គវាស្សញ្ច មាស្ស យុញ្ជ យថា បុរេ
បរិហារញ្ច ទជ្ជាសិ អធិការកតោ ពលិ" ។

សូមព្រះអង្គកុំទឹមគោនិងសេះ ជាសត្វចិញ្ចឹមចាស់ ៗ ដូចក្នុងកាលមុនឡើយ សត្វណាមាន កម្លាំងធ្វើឧបការៈច្រើនដល់ព្រះអង្គ ៗ ចូរប្រទានការរក្សាដល់សត្វនោះផង ។

ដោយប្រការដូចដែលពោលមកនេះ ព្រះមហាសត្តបានសម្តែងនូវទានកថា[៨៩] ផង សីលកថា[៩០] ផង ថ្វាយព្រះរាជា ។ ហេតុតែព្រះរាជាអង្គនេះទ្រង់ត្រេកអរនឹងការពណ៌នាដែលប្រៀបធៀបអត្តភាពរបស់ព្រះអង្គថាដូចជារថ, ដូច្នោះ ឥសីពោធិសត្វបានបន្តសម្តែងនូវធម៌ដោយឧបមាដូចរថដែលឲ្យសម្រេចក្តីប្រាថ្នាគ្រប់យ៉ាងដល់ព្រះរាជាអង្គនោះដូច្នេះ ៖

កាយោ តេ រថសញ្ញាតោ    មនោសារថិកោ លហុ
អវិហឹសាសារិតក្ខោ    សំវិភាគបដិច្ឆទោ ។

កាយរបស់ព្រះអង្គចូរសម្គាល់ថាដូចរថ មានចិត្តជានាយសារថី ជាកាយរហ័សរហួន មានការមិនបៀតបៀនជាភ្លៅដែលគេសម្រេចល្អហើយ មានការចែករំលែកទានជាផ្ទុះ[៩១] ។

ចាគសញ្ញមនេមិយោ    ហត្ថសញ្ញមបក្ខរោ
កុច្ឆិសញ្ញមនព្ភន្តោ    វាចាសញ្ញមកូជនោ ។

[៨៩] ការពោលអំពីទាន ពីរបៀបធ្វើទាននិងអានិសង្សរបស់ទាន ។

[៩០] ការពោលអំពីសីល របៀបរក្សាសីល និងអានិសង្សរបស់សីល ។

[៩១] ដំបូលរទេះ (ហៅក្លាយជា ផ្ទុល ឬ ផ្ទូរ ក៏មាន) ។

មានការសង្រួមជើងជាខ្នងកង់[៩២]មានការសង្រួមដៃជាទ្រពង់[៩៣]
មានការសង្រួមផ្ទៃជាប្រេងលាបការសង្រួមវាចាជាការស្ងាត់ស្ងៀម ។

សច្ចវាក្យសមង្គង្គោ　　អបេសុញ្ញសុសញ្ញតោ
គិរាសខិលនេលង្គោ　　មិតភាណិសិលេសិតោ ។

មានពាក្យពិតជាតួនៃរថដ៏បរិបូណ៌ មានការមិនញុះញង់ជា
ដំណាប់[៩៤]ជិតល្អ មានវាចាពីរោះជាតួនៃរថ មិនមានទោស គឺថា
រលីង មានការពោលល្មមប្រមាណ ជាគ្រឿងចង ។

សទ្ធាលោភសុសង្ខារោ　　និវាតញ្ជលិកុព្វរោ
អថទ្ធតានតីសាកោ　　សីលសំវរនន្ធនោ ។

---

[៩២] ប្រដាប់រទេះធ្វើពីឈើមានរង់ព័ទ្ធជុំវិញចុងកាំ : ខ្នងកង់រទេះ ។

[៩៣] ឈើវែង១គូដែលប្រើជាមេសម្រាប់ដាក់ខាងលើខ្នង់ឬជើងទៀនរទេះទុកដូចជា
ភ្នាក់ដៃ : ទ្រពង់រទេះ ។

[៩៤] រណ្ដៅ, រន្ធ ដែលកើតពីដាប់ : ដំណាប់សសរ ។

*មានសទ្ធានិងអលោភៈជាគ្រឿងប្រដាប់រថ មានការបន្ទន់បន្ទាបខ្លួននិងអញ្ជលីកម្ម[៩៥]ជាទូក មានការមិនរឹងត្អឹងជាចន្ទោលរថ[៩៦] មានការសង្រួមក្នុងសីលជាព្រ័ត្រជ្រាម[៩៧] ។*

អក្កោធនមនុគ្ឃាតី ធម្មបណ្ឌរឆត្តកោ
ពាហុសច្ចមចាលម្ពោ ឋិតចិត្តមុចាធិយោ ។

*មានការមិនក្រោធ[៩៨]ជាការមិនសណ្ដក មានសុចរិតធម៌[៩៩]ជាឆត្រស មានពាហុសច្ចៈ[១០០] ជាខ្សែចន្ទោល មានចិត្តតាំងនៅនឹងជាអាសនៈ[១០១] ។*

---

[៩៥] *ការធ្វើអញ្ជលី គឺការលើកក្រពុំម្រាមដៃទាំង ១០ សំពះគោរព ។*

[៩៦] *ឈើមានសណ្ឋាន-ង តភ្ជាប់នឹងក្បាលក្រពើរទេះ សម្រាប់ចងខ្សែទាញមកចងភ្ជាប់នឹងកន្ទុះគោ, ក្របី; ខ្សែដែលចងនោះ ហៅថា ខ្សែចន្ទោល តាមចន្ទោលរទេះនោះដែរ ។*

[៩៧] *ចំណាងដែលចងជ្រាម ។ ខ្សែ, ពួរ, ព្រ័ត្រចងជ្រាមក៏ហៅថា ខ្សែជ្រាម, ពួរជ្រាម, ព្រ័ត្រជ្រាម ដែរ ។*

*៩៨ ("កំហឹង") តែក្នុងប្រទេសយើងប្រើជា កិ. "ខឹង" ក៏បាន : កុំអាលក្រោធ ។*

*(ន.) (សំ.) កំហឹង : ស្ដីឲ្យដោយក្រោធខ្លាំង គឺស្ដីឲ្យដោយកំហឹងខ្លាំង ។*

កាលញ្ញុតាចិត្តសារោ　　វេសារជ្ជតិឧណ្ណកោ;
និវាតវុត្តិយោត្តកោ　　អនតិមានយុគោ លហុ ។

មានការដឹងកាល ជាឈើខ្លឹមដ៏វិចិត្រ មានសេចក្តីក្លៀវក្លា ជាចន្ទល់[១០២] មានការប្រព្រឹត្តបន្ទន់ខ្លួនជាខ្សែ មានការមិនមើលងាយជានឹម[១០៣] ដ៏ស្រាល ។

អលីនចិត្តសន្ថារោ　　វុទ្ធិសេវី រជោហតោ

---

[៩៩] ធម៌ល្អមាន ៣ យ៉ាងគឺ ការប្រព្រឹត្តល្អដោយកាយ ហៅ កាយសុចរិត;... ដោយវាចា ហៅ វចីសុចរិត; ... ដោយចិត្តសុទ្ធ ហៅ មនោសុចរិត ។

[១០០] ភាវៈនៃបុគ្គលជាពហុស្សូត គឺការតាំងចិត្តរៀនសូត្រមុតមាំ ឬការចេះដឹងច្រើនព្រោះសេចក្តីខំប្រឹងរៀន (នៃអ្នកសិក្សា) : មនុស្សមានពាហុសច្ច ។

[១០១] ទីអង្គុយ, កន្លែងអង្គុយ, កម្រាលឬប្រដាប់សម្រាប់អង្គុយ : អង្គុយលើអាសនៈស្មើគ្នា ។ ព. កា. ច្រើនប្រើ អាសន៍ ជាង : កុំអាលច្រឡាស អង្គុយដើមអាសន៍ រួចបែរជាថយ ចុះមកចុងអាសន៍ ឲ្យខ្មាសស្តាយក្រោយ ប្រយ័ត្នកុំឆ្គោយ ឲ្យខ្សោយភាពខ្លួន ។

[១០២] ប្រដាប់សម្រាប់ទល់ : ចន្ទល់ផ្ទះ, ចន្ទល់រទេះ ។

[១០៣] ប្រដាប់រទេះសម្រាប់ទឹមគូសត្វពាហនៈ ដែលត្រូវអូសត្រូវទាញរទេះឬគាវជាដើម : នឹមរទេះ,នឹមនង្គ័ល ។ គូ (សត្វពាហនៈ) : គោមួយនឹម គឺគោមួយគូដែលទឹមប៉ះគ្នា ។

សតិបតោទោ ធីរស្ស ធិតិ យោគោ ច រស្មិយោ។

មានចិត្តមិនរួញរាជាកម្រាល មានការសេពសេចក្តីចម្រើនដោយបញ្ញាជាអំបោស សតិរបស់ព្រះអង្គជាអ្នកប្រាជ្ញ ទុកជាជន្ទួញមានព្យាយាមដ៏មាំ និងការប្រកបជាខ្សែបរ ។

មនោ ទន្តំ បថំ នេតិ សមទន្តេហិ វាហិភិ
ឥច្ឆា លោភោ ច កុម្មគ្គោ ឧជុមគ្គោ ច សំយមោ ។

ចិត្តដែលទូន្មានល្អហើយ រមែងទៅកាន់ផ្លូវដូចរថដែលទៅកាន់ផ្លូវត្រង់ដោយសារសេះទាំងឡាយដែលនាយសារថីហ្វឹកហ្វឺនល្អ ហើយព្រោះសេចក្តីប្រាថ្នានិងសេចក្តីលោភជាផ្លូវខុស ការសង្រួមជាផ្លូវត្រង់ ។

រូបេ សទ្ទេ រសេ គន្ធេ វាហនស្ស បធាវតោ
បញ្ញា អាកោដនី រាជ តត្ថ អត្តាវ សារថិ។

បពិត្រព្រះរាជា កាលបើរថគឺកាយរបស់ព្រះអង្គស្មុះទៅក្នុងរូប សំឡេង ក្លិន រស តួបញ្ញាជាជន្ទួញ[១០៤]សម្រាប់គោះ ឯតួខ្លួនព្រះអង្គជានាយសារថីក្នុងរថនោះ ។

សចេ ឯតេន យានេន          សមចរិយា ទឡ្ហា ធិតិ
សព្វកាមទុហោ រាជ          ន ជាតុ និរយំ វជេ។

បពិត្រព្រះរាជា ប្រសិនបើការប្រព្រឹត្តស្មើ និងសេចក្តីព្យាយាមដ៏មាំដោយយានគឺកាយនោះ ការបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាងក៏កើតមានសត្វមិនទៅកាន់នរកដោយដាច់ខាត” ។

ឥសីពោធិសត្វ លុះសម្តែងនូវធម៌ដល់ព្រះរាជាយ៉ាងនេះហើយ ក៏បានពន្យល់ព្រះរាជាឲ្យលះបង់នូវមិច្ឆាទិដ្ឋិ ឲ្យតាំងនៅស៊ប់ក្នុងសីល រួចផ្តល់ដំបូន្មានថា “ចាប់ពីថ្ងៃនេះតទៅ ព្រះអង្គចូរលះបង់បាបមិត្រទាំងឡាយ ហើយចូរចូលទៅរកកល្យាណមិត្រទាំងឡាយ ចូរកុំប្រហែសធ្វេសជានិច្ចកាល” ។ បន្ទាប់មក ឥសីបានពណ៌នាគុណរបស់រាជធីតា ផ្តល់នូវឱវាទដល់រាជបរិស័ទផង ដល់ស្រីស្នំផង ។ ដោយអានុភាពដ៏ធំ

[១០៤] ដែកស្រួចមានដងសម្រាប់ចាក់គោ : ជន្ទួញសម្រាប់ប្រើចាក់គូទគោ ។

នោះ ឥសីពោធិសត្វយាងទៅកាន់ព្រហ្មលោកវិញ មហាជនទាំងអស់បានមើលឃើញជាក់ច្បាស់នឹងភ្នែកគ្រប់គ្នា ។

## ព្រះសាស្តាប្រជុំជាតក

ព្រះសាស្តាបរមគ្រូនៃយើង លុះនាំធម្មទេសនានេះមកបរិយាយហើយ ទ្រង់បញ្ជាក់ថា "ម្នាលភិក្ខុទាំងឡាយមិនមែនតែឥឡូវនេះ សូម្បីពីអតីតជាតិ ក៏តថាគតធ្លាប់បំបែកបណ្តាញទិដ្ឋិហើយទូន្មានឧរុវេលកស្សបអ៊ីចឹងដែរ" ។ បន្ទាប់មក ទ្រង់ត្រាស់ប្រជុំជាតកដូច្នេះ ៖

- អលាតសេនាបតី បានមកជាទេវទត្ត
- សុនាមអាមាត្យ បានមកជាភទ្ទជិ
- វិជយអាមាត្យ បានមកជាសារីបុត្ត
- វីជកទាសៈ បានមកជាមោគ្គល្លាន
- អចេលកៈឈ្មោះ គុណៈ បានមកជាសុនក្ខត្តលិច្ឆវីបុត្រ
- នាងរុចាដែលបានញុំាងព្រះរាជាឲ្យជ្រះថ្លា បានមកជាអានន្ទ

- ព្រះរាជាអង្គតិដែលមានទិដ្ឋិអាក្រក់ក្នុងកាលនោះ បានមកជាឧរុវេលកស្សប

- នារទមហាព្រហ្មពោធិសត្វ  បានមកជាអញតថាគតនេះឯង អ្នកទាំងឡាយចូរចាំទុកនូវជាតកដូចសម្ដែងមកនេះ ។

មហានារទកស្សបជាតកទី ៨ ចប់តែប៉ុណ្ណោះ ។

PAÑÑĀSĀSTRA UNIVERSITY



ISBN 9789995094683

PUC Press